# របាយការណ៍លទ្ធផលសិក្សាស្រាវជ្រាវ

# ស្តីពី

# ការប្រើប្រាស់មូលនិធិវិនិយោគវិស័យ

# របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ក្នុងការគាំទ្រ

# ដល់គំរោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់


រៀបចំដោយ

ក្រុមការងារកម្មវិធី សិលា ក្រសួងអភិវឌ្ឍន៍ជនបទ



ថ្ងៃទី ១ មិថុនា - កក្កដា ២០០៥



307.14 REP

បណ្ណាល័យ
គ.ជ.អ.ប

# មាតិការអត្ថបទ


| ល.រ | ចំណងជើងមាតិកា | ទំព័រ |
|---|---|---|
| ១ | សេចក្តីផ្តើម................................................................ | ១ |
| ២ | គោលបំណងនៃការសិក្សាស្រាវជ្រាវ.................................................. | ២ |
| ៣ | វិធីសាស្រ្តក្នុងការសិក្សា................................................................ | ២-៣ |
| ៤ | គំហើញនៃការសិក្សា | |
| | ៤.១. ការបែងចែកថវិកា PIF ទៅមន្ទីរអ.ជ.ប ដើម្បីគាំទ្រផែនការវិនិយោគរបស់ឃុំ.......... | ៣-៥ |
| | ៤.២. ការឆ្លើយតបរបស់មន្ទីរអ.ជ.ប ដើម្បីគាំទ្រដល់ផែនការ CIP របស់ឃុំ..................... | ៥-៧ |
| | ៤.៣. ការប្រើប្រាស់ថវិកា PIF ដើម្បីគាំទ្រគំរោងផ្តល់សេវាកម្ម និងគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទ | ៧-៨ |
| | ៤.៤. កិច្ចសហការ និងការសំរបសំរួលរវាងថវិកា PIF របស់មន្ទីរអ.ជ.ប និងមូលនិធិឃុំ....... | ៨ |
| | ៤.៥. កិច្ចសហការ និងការទំនាក់ទំនងរវាងក្រុមការងារមន្ទីរអ.ជ.ប និងផ្នែកគាំទ្របច្ចេកទេសនៃគ.ប្រ | ៨-៩ |
| ៥ | សេចក្តីសន្និដ្ឋាន និងអនុសាសន៍........................................................ | ១០-១១ |


**ឧបសម្ព័ន្ធ**


១ តារាងថវិកា PIF មន្ទីរអ.ជ.ប ទាំង ២៤ ខេត្ត-ក្រុងដែលបានទទួលក្នុងឆ្នាំ ២០០៥ ។

២ បញ្ជីសំណួរ ។

៣ ការណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងអ.ជ.ប ទៅមន្ទីរអ.ជ.បខេត្ត-ក្រុង ដើម្បីត្រៀមលើកផែនការឆ្នាំ ២០០៦-២០០៧ ។

៤ អនុសាសន៍ក្រុមវាយតម្លៃគំរោងផ្គត់ផ្គង់ទឹកស្អាត នៃនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ។

៥ អនុសាសន៍ក្រុមវាយតម្លៃគំរោងផ្លូវលំ នៃនាយកដ្ឋានផ្លូវលំជនបទ


307.14
REP
sh: Rural Development

NCDD Library
002015

# របាយការណ៍សិក្សាស្រាវជ្រាវ
# ស្តីពី
# ការប្រើប្រាស់មូលនិធិវិនិយោគវិស័យរបស់មន្ទីរអភិវឌ្ឍន៍ជនបទ
# ក្នុងការគាំទ្រដល់គំរោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់
# ថ្ងៃទី ១ មិថុនា - កក្កដា ២០០៥

## I. សេចក្តីផ្តើម

កម្មវិធី សិលា ជាកម្មវិធីរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រ ដល់ដំណើរការអនុវត្តន៍គោលនយោបាយវិមជ្ឈការរបស់រាជរដ្ឋាភិបាល ។ នៅឆ្នាំ ២០០២ រាជរដ្ឋាភិបាលកម្ពុជា បានសំរេចរៀបចំបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ទូទាំងប្រទេស ។ ក្រោយពីក្រុមប្រឹក្សាឃុំ-សង្កាត់ បានកើតជារូបរាងនិងចាប់ផ្តើមដំណើរការ កម្មវិធីសិលា បានដើរតួនាទីជាកម្មវិធីស្នូលមួយក្នុងការគាំទ្រកិច្ចដំណើរការអភិវឌ្ឍន៍មូលដ្ឋានរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ក្នុងនោះមានដូចជាការបណ្តុះបណ្តាលសមាជិកក្រុមប្រឹក្សា ស្មៀន និងមន្ត្រីពាក់ព័ន្ធនានាក្នុងការគាំទ្រដល់ឃុំ និងការផ្តល់សេវាកម្ម។

ឆ្លើយតបទៅនឹងតំរូវការខាងលើនេះ មន្ទីរអ.ជ.បមានតួនាទីមួយដ៏សំខាន់ក្នុងការគាំទ្រ និងជួយលើការងារបច្ចេកទេសនានាស្របតាមបេសកកម្ម និងការទទួលខុសត្រូវរបស់មន្ទីរ ក្នុងការរួមចំណែកអភិវឌ្ឍន៍មូលដ្ឋានតាមផែនការរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្នុងនោះមន្ទីរមានតួនាទីពីរ ដែលត្រូវសហការនិងសំរបសំរួលអោយបានជិតស្និទ្ធជាមួយនឹងក្រុមប្រឹក្សាឃុំ-សង្កាត់ គឺ ទីមួយការប្រើប្រាស់ថវិកាវិនិយោគវិស័យ (PIF) ដែលមន្ទីរបានទទួលពីគណៈកម្មាធិការប្រតិបត្តិ (គ.ប្រ) ក្នុងការគាំទ្រដល់ផែនការវិនិយោគរបស់ឃុំ-សង្កាត់ និងទីពីរការទទួលខុសត្រូវក្នុងការគ្រប់គ្រងផ្នែកគាំទ្របច្ចេកទេសនៃរចនាសម្ព័ន្ធគ.ប្រ ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ-សង្កាត់លើការសាងសង់សំណង់ហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្តនៅក្នុងឃុំ-សង្កាត់ ។

ដោយផ្អែកតាមតួនាទីដ៏សំខាន់ទាំងពីរខាងលើនេះ ក្រុមការងារ សិលា ក្រសួង អ.ជ.ប បានផ្តួចផ្តើមគំនិតដើម្បីធ្វើការសិក្សាស្រាវជ្រាវពីតួនាទីទាំងពីររបស់មន្ទីរអ.ជ.ប តើមានការឆ្លើយតបអោយគ្នាទៅវិញទៅមកដែរឬទេ ? តើមន្ទីរ អ.ជ.ប បានប្រើប្រាស់ថវិកា PIF ប្រកបដោយប្រសិទ្ធភាពយ៉ាងណាខ្លះ ? តើមន្ទីរ អ.ជ.ប និង ផ្នែកគាំទ្របច្ចេកទេសនៃរចនាសម្ព័ន្ធគ.ប្រ មានការសហការគ្នាក្នុងករណី និងចែករំលែកបទពិសោធន៍ ឬពតិមាននានាដែលទាក់ទងនឹងការពង្រឹងការសាងសង់ និងប្រើប្រាស់-ថែទាំសំណង់ហេដ្ឋារចនាសម្ព័ន្ធនៅជនបទរបៀបណា ?

## II. គោលបំណងនៃការសិក្សាស្រាវជ្រាវ

១. ស្វែងយល់ពីការបែងចែកថវិកា PIF របស់គ.ប្រ ដល់មន្ទីរ អ.ជ.ប ៧ ដែលជាតំណាងអោយមន្ទីរ អ.ជ.ប ទាំង ២៤ ខេត្ត-ក្រុង ដើម្បីប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងតំរូវការរបស់ឃុំ-សង្កាត់ ។

២. ស្វែងយល់ពីប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកា PIF របស់មន្ទីរ អ.ជ.ប ក្នុងការឆ្លើយតបទៅនឹងតំរូវការរបស់ឃុំ-សង្កាត់ និងកិច្ចសហការ-សំរបសំរួលរបស់មន្ទីរ អ.ជ.ប ក្នុងការប្រើប្រាស់ថវិកា PIF និងថវិកាមូលនិធិឃុំ-សង្កាត់ (C/S Fund) របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

៣. ស្វែងយល់ពីកិច្ចសហការ និង ការទំនាក់ទំនងរវាងមន្ទីរអ.ជ.ប និងផ្នែកគាំទ្របច្ចេកទេសនៃគណៈកម្មាធិការប្រតិបត្តិ ។

## III. វិធីសាស្ត្រដែលប្រើក្នុងការសិក្សាស្រាវជ្រាវ

### ៣.១. ការជ្រើសរើសខេត្តគោលដៅទាំង ៧ ដែលត្រូវចុះសិក្សាស្រាវជ្រាវ និងពេលវេលា

ដោយផ្អែកតាមតួលេខថវិកា PIF ដែលក្រុមការងារ សិលា ទទួលបានពីបណ្តាមន្ទីរ អ.ជ.ប ទាំង ២៤ ខេត្ត-ក្រុង ក្រុមសិក្សាបានសំរេចជ្រើសរើសយកខេត្តទាំង ៧ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដូចតទៅ : (១) ខេត្តដែលបានទទួលថវិកា PIF ច្រើនបំផុតក្នុងឆ្នាំ ២០០៥ , (២) ខេត្តដែលបានទទួលថវិកា PIF តិចបំផុតក្នុងឆ្នាំ ២០០៥ , (៣) ខេត្តដែលមិនបានទទួលថវិកា PIF ក្នុងឆ្នាំ ២០០៥ ។ ផ្អែកតាមការវិនិច្ឆ័យខាងលើនេះយើងសំរេចជ្រើសរើសខេត្តចំនួន ៧ ក្នុងចំណោម ២៤ ខេត្ត-ក្រុង ដោយការជ្រើសរើសខេត្តនិមួយៗត្រូវយកតាមបណ្តាភូមិភាគ និងចាប់អនុវត្តពីថ្ងៃទី ១ មិថុនា ដល់ថ្ងៃទី ១ កក្កដា ២០០៥ ។

១. ខេត្តភាគខាងកើត : ជ្រើសរើសយក ២ ខេត្ត គឺ ខេត្តដែលបានទទួលថវិកា PIF ច្រើនចំនួនមួយខេត្ត និង ខេត្តដែលបានទទួលថវិកា PIF តិចចំនួនមួយខេត្ត ។

២. ខេត្តភាគខាងលិច : ជ្រើសរើសយក ២ ខេត្ត គឺ ខេត្តដែលបានទទួលថវិកា PIF ច្រើនចំនួនមួយខេត្ត និង ខេត្តដែលបានទទួលថវិកា PIF តិចចំនួនមួយខេត្ត ។

៣. ខេត្តភាគខាងត្បូង : ជ្រើសរើសយក ២ ខេត្ត គឺ ខេត្តដែលបានទទួលថវិកា PIF ច្រើនចំនួនមួយខេត្ត និង ខេត្តដែលបានទទួលថវិកា PIF តិចចំនួនមួយខេត្ត ។

៤. [1]ខេត្តភាគខាងជើង ឬ ភូមិភាគឥសាន្ត : ចំនួន ១ ខេត្ត គឺ ខេត្តដែលមិនបានទទួលថវិកា PIF ។

---

[1] ខេត្តរតនគិរី និងមណ្ឌលគិរីជាខេត្តមួយដែលខ្វះធនធានមនុស្ស ក្រុមសិក្សាបានសំរេចប្តូរទៅខេត្តស្ទឹងត្រែងវិញ ។

| ទីតាំង | ខេត្តគោលដៅ | ថវិកា PIF ដែលបានទទួល | ឃុំគោលដៅ |
|---|---|---|---|
| ភូមិភាគខាងកើត | ១. ក្រចេះ | ២៥.៨០០ $ | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| | ២. កំពង់ចាម | ៣០.០០០ $ | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| ភូមិភាគខាងលិច | ១. បន្ទាយមានជ័យ | ២២.០០០ $ | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| | ២. ពោធិ៍សាត់ | ១៥.០០០ $ | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| ភូមិភាគខាងត្បូង | ១. កែប | ៧.០០០ $ | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| | ២. [2] ឧត្តរមានជ័យ | អត់មានថវិកា PIF | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| ភូមិភាគខាងជើង | ១. ស្ទឹងត្រែង | ៣៥.៧៥០ $ | ១-២ ឃុំដែលបានទទួលការគាំទ្រពីមន្ទីរ |
| សរុប : | ៧ ខេត្ត | | ៧-១៤ ឃុំ |

### ៣.២. ការរៀបចំបញ្ជីសំណួរដើម្បីសម្ភាសន៍អ្នកពាក់ព័ន្ធ

ដើម្បីប្រមូលព័ត៌មាន ក្រុមសិក្សាបានរៀបចំសំណួរមួយចំនួន ក្នុងការតំរង់ទិសការពិភាក្សាជាមួយអ្នកពាក់ព័ន្ធដែលជួបសម្ភាសន៍ ។ សំណួរទាំងនោះបានយកទៅធ្វើតេស្តសាកល្បងនៅក្នុងខេត្តតាកែវ ។ ផ្អែកតាមគោលបំណងទាំងបីនៃការសិក្សា សំណួរបានរៀបចំឡើងដោយក្តោបទៅលើចំណុចសំខាន់ៗទៅតាមគោលបំណងនិមួយៗ ។ អ្នកដែលពាក់ព័ន្ធក្នុងការជួបពិភាក្សាលើសំណួរទាំងអស់នោះ ក្រុមសិក្សាបានចែកចេញជាពីរមុខសញ្ញា គឺ:

ក្រុមគោលដៅដែលត្រូវជួបសម្ភាសន៍ដោយផ្ទាល់ :

១. ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ និង ក្រុមការងារក្នុងការទទួលខុសត្រូវថវិកា PIF របស់មន្ទីរ ។

២. ប្រធាន និង អនុប្រធានផ្នែកគាំទ្របច្ចេកទេសនៃរចនាសម្ព័ន្ធ គ.ប្រ ។

៣. ក្រុមប្រឹក្សាឃុំនៃឃុំគោលដៅដែលក្រុមសិក្សាបានជ្រើសរើសយកតាមការចុចយក ។

ក្រុមគោលដៅដែលត្រូវជួបសម្ភាសន៍ដោយប្រយោល :

១. មន្ត្រី PLG ទទួលបន្ទុកថវិកាវិស័យ ។

២. មន្ត្រីផ្នែកគ្រប់គ្រងកិច្ចសន្យា (CAU) នៃរចនាសម្ព័ន្ធ គ.ប្រ ។

## IV. គំហើញនៃការសិក្សា

### ៤.១. ការបែងចែកថវិកា PIF ទៅមន្ទីរ អ.ជ.ប ដើម្បីគាំទ្រផែនការវិនិយោគរបស់ឃុំ (CIP)

ជាទូទៅយើងឃើញថាមន្ទីរ អ.ជ.ប បានរៀបចំផែនការ ដោយពុំមានលក្ខណៈស្តង់ដារឬមានការ

[2] ត្រូវជំនួសដោយខេត្តព្រៃវែងវិញ ពីព្រោះខេត្តនេះមិនមានថវិកា PIF ដែលទទួលពីកម្មវិធី សិលា តែមានថវិកា PIF ពី UNICEF

ណែនាំណាមួយពីថ្នាក់ជាតិទេ ដូច្នេះខេត្តខ្លះយើងឃើញថាផ្តោតខ្លាំងលើការសាងសង់ ដោយមិនមានលើកគំរោងថែទាំ-ជួសជុលឡើយ **ហើយក៏មិនមានលើកគំរោងកសាងសមត្ថភាពមន្ត្រីរបស់ខ្លួនដែរ ទោះបីដឹងថាខ្លួនខ្វះធនធានមនុស្សដើម្បីបំរើការងារក៏ឡើយ** ។ គ.ប្របានវិភាជន៍ថវិកាអោយមន្ទីរ ក្នុងអំឡុងខែកញ្ញាជារៀងរាល់ឆ្នាំ នៅពេលគ.ប្របានដឹងតួលេខថវិកាប្រចាំឆ្នាំពីអគ្គលេខាធិការដ្ឋាន STF ហើយមន្ទីរត្រូវរៀបចំផែនការរបស់ខ្លួនដាក់ជូនគ.ប្រពិនិត្យនិងអនុម័ត ផែនការរបស់មន្ទីរនោះត្រូវឆ្លើយទៅឃុំក្នុងខែតុលានៅពេលសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ។ ផែនការដែលមន្ទីរបានលើកឡើងមានដូចជា ការសាង់សង់ផ្លូវលំ គំរោងជីកអណ្តូងទឹក , គំរោងដាក់លូកាត់ថ្នល់ , គំរោងជួសជុលអណ្តូងស្នប់ឬលូ , គំរោងអប់រំក្រុមប្រើប្រាស់ទឹកស្អាតនិងអនាម័យ , គំរោងបណ្តុះបណ្តាលគណៈកម្មការថែទាំផ្លូវលំ , គំរោងជួសជុលផ្លូវ , គំរោងផ្តល់សំភារៈសាងសង់បង្គន់អនាម័យតាមគ្រួសារ , គំរោងផ្តល់ធុងចំរោះទឹកស្អាត , សាងសង់ស្ពានឈើ , គំរោងចុះស្រង់ទិន្នន័យអណ្តូង ។

ផែនការដែលមន្ទីរលើកឡើងត្រូវឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យ ១១ ចំណុច ដែលគ.ប្របានណែនាំដូចជា ផែនការនោះត្រូវឆ្លើយតបនឹងតំរូវការរបស់ឃុំនៅក្នុង CIP (Commune Investment Plan/តារាង Matrix របស់ឃុំ ), ផែនការនោះឆ្លើយតបនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល , មន្ទីរនោះប្រើប្រាស់ថវិកា PIF ឆ្នាំចាស់បានអស់ត្រឹមត្រូវតាមផែនការខ្លួនបានលើក , ផែនការរបស់មន្ទីរមាននៅក្នុងផែនការអភិវឌ្ឍន៍របស់ខេត្ត (PDP), ផែនការនោះស្របតាមអាណត្តិរបស់ខ្លួន ។ល ។

មន្ទីរខេត្តមានការលំបាកនឹងបញ្ចុះបញ្ចូលអោយគ.ប្រ ទទួលយកតំរូវការផែនការរបស់ខ្លួនដែលបានលើក ទោះបីជាផែនការនោះស្របតាមលក្ខខ័ណ្ឌទាំងអស់ដែលគ.ប្របានណែនាំក៏ដោយ ដូច្នេះមន្ទីរត្រូវសំរបសំរួលទៅតាមអ្វីដែលគ.ប្រចង់បាននិងអនុម័តគាំទ្រ ។ **ជាបទពិសោធន៍ល្អនៅក្នុងខេត្តពោធិ៍សាត់ មន្ទីរបានទទួលការណែនាំពីគ.ប្រអោយមន្ត្រីរបស់ខ្លួន ចុះទៅតាមឃុំនិមួយៗនៅពេលឃុំកំពុងពិនិត្យឡើងវិញ CIP (ជំហាន ទី ១) ដើម្បីជួយសំរបសំរួលសកម្មភាពសំខាន់ៗដែលឃុំមិនបានលើកឡើង ដូចជា ការបណ្តុះបណ្តាលគណៈកម្មការថែទាំផ្លូវ ឬអណ្តូងទឹកជាដើម** ។ ប៉ុន្តែគ.ប្រ ខេត្តខ្លះបានគិតថាការរៀបចំគណៈកម្មការនិងបណ្តុះបណ្តាលគណៈកម្មការទាំងនោះ គឺ ជាបន្ទុករបស់មន្ទីរដែលត្រូវផ្តល់ជូនទៅឃុំ នៅពេលដែលមន្ទីរគ្មានថវិការៀបចំ ឬបណ្តុះបណ្តាលគណៈកម្មការ បានធ្វើអោយគំរោងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនក្នុងឃុំ គ្មានការថែទាំ ។

ការលើកផែនការទាមទារអោយមានភាពសុក្រិតសំរាប់ដាក់ជូនគ.ប្រពិនិត្យនិងអនុម័ត មន្ទីរខ្លះមិនមានមន្ត្រីដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីចុះសិក្សាគំរោងអោយបានលំអិតសំរាប់លើកផែនការទេ ។

ជាក់ស្តែងមន្ទីរ អ.ជ.ប ខេត្តក្រចេះបានលើកគំរោងធ្វើផ្លូវ និងធ្វើស្ពានឈើមានតម្លៃថោកជាងតម្លៃជាក់ស្តែងនៃការអនុវត្តន៏គំរោង ។ **ដើម្បីកែលំអបញ្ហានេះ មន្ទីរគួរតែស្នើសុំទៅមន្ត្រីផ្នែកគាំទ្របច្ចេកទេស (TSU) ដើម្បីអោយគេជួយ ឬមួយមន្ទីរខិតខំកសាងសមត្ថភាពមន្ត្រីរបស់ខ្លួន ដោយស្នើសុំទៅទីប្រឹក្សាបច្ចេកទេស PLG ឬមន្ត្រីគាំទ្របច្ចេកទេសជួយផ្តល់វគ្គបណ្តុះបណ្តាលខ្លីៗដល់បុគ្គលិកមន្ទីរ ហើយមន្ទីរគួរបញ្ចូលសកម្មភាពកសាងសមត្ថភាពមន្ត្រីរបស់ខ្លួនទៅក្នុងផែនការ** ។

ដើម្បីគ្រប់គ្រងថវិកា PIF មន្ទីរបានរៀបចំក្រុមការងារមួយដែលមានសមាសភាពពី ៥-៦ នាក់ ក្នុងនោះមានមន្ត្រីអនុម័ត ( ជាប្រធាន ឬអនុប្រធានមន្ទីរ ) មន្ត្រីអនុម័តផ្ទេរសិទ្ធិ មន្ត្រីទទួលបន្ទុកការងារទិកស្ទាត និងអនាម័យ , មន្ត្រីទទួលបន្ទុកផ្លូវលំ , មន្ត្រីពិនិត្យបញ្ជាក់ និងមន្ត្រីបេឡាក ។ មានខេត្តមួយចំនួនមានការផ្លាស់ប្តូរប្រធានមន្ទីរ នៅពេលដែលប្រធានមន្ទីរថ្មីចូលកាន់មុខដំណែងក៏មានការផ្លាស់ប្តូរមន្ត្រីទាំងនោះផងដែរ ហើយបញ្ហាខ្លះមន្ត្រីដែលទទួលបន្ទុកការងារនិមួយៗ នៅពេលមានបេសកកម្មទៅឆ្ងាយមិនបានទុកពត៌មានអោយអ្នកនៅកន្លែងទេ។ **នេះជាការបញ្ហាមួយដែលត្រូវកែលំអ គឺពត៌មានការអនុវត្តន៏កម្មវិធី សិលា ត្រូវមានការចែករំលែកពត៌មានទាំងនោះអោយក្រុមការងារ សិលា របស់មន្ទីរបានដឹងឮទាំងអស់គ្នា ឬប្រធានដែលជាមន្ត្រីអនុម័តត្រូវក្តាប់ការងារនេះអោយបាន ដើម្បីងាយស្រួលក្នុងការទំនាក់ទំនងជាមួយនឹង គ.ប្រ និងទីប្រឹក្សារបស់ PLG** ។

### ៤.២. ការឆ្លើយតបរបស់មន្ទីរ អ.ជ.ប ដើម្បីគាំទ្រដល់ផែនការ CIP របស់ឃុំ

ស្របតាមលក្ខណៈវិនិច្ឆ័យដែលគ.ប្របានណែនាំ ថវិកា PIF របស់មន្ទីរសុទ្ធតែបានគាំទ្រទៅនឹងតំរូវការរបស់ឃុំ ។ ដោយសារថវិកា PIF មានកំណត់ ការឆ្លើយតបរបស់មន្ទីរមិនបានគ្រប់ឃុំទាំងអស់ទេ ដូច្នេះមានឃុំជាច្រើនដែលមន្ទីរមិនមានលទ្ធភាពឆ្លើយតបនៅក្នុងសិក្ខាសាលាសមាហរណកម្ម ។ **ជាការល្អថវិកា PIF គួរកំណត់នឹងប្រើទៅលើមន្ទីរដែលអាទិភាពមួយចំនួន ដូចជាមន្ទីរអ.ជ.ប , ធនធានទឹក , កសិកម្ម អប់រំ , សុខាភិបាល** ។ល។ ជាដើម ។ ខេត្តខ្លះគ.ប្របានចែករំលែកថវិកា PIF ទៅមន្ទីរមិនអាទិភាពក្នុងការគាំទ្រគំរោងរបស់ឃុំ ដោយមន្ទីរទាំងនោះបានទទួលត្រឹមតែ ២.០០០ ទៅ ៤.០០០ USD ឯថវិកាសំរាប់មន្ទីរសំខាន់ៗគាំទ្រទៅឃុំត្រូវកាត់បន្ថយ ។ ដូច្នេះយើងឃើញថា ការបែងចែក PIF ខេត្តខ្លះមានលក្ខណៈជាបរិមាណច្រើនជាងគុណភាពក្នុងការប្រើថវិកា PIF សំរាប់គាំទ្រគំរោងអភិវឌ្ឍន៏របស់ឃុំ ។

ដើម្បីដោះស្រាយបញ្ហានេះ មន្ទីរខ្លះដែលបានទទួលថវិកាពីក្រសួង ( ជាពិសេសថវិការដ្ឋដែលបានទទួលពីនាយកដ្ឋានផ្លូវលំ ) បានយកទៅប្រើប្រាស់នៅក្នុងការឆ្លើយតបទៅឃុំដែលខ្លួនមិនមានថវិកា PIF ជួយគាំទ្រ ជាទូទៅយើងឃើញថា ថវិការដ្ឋដែលមន្ទីរបានទទួលពីថ្នាក់ជាតិ គឺមានតែនាយកដ្ឋានផ្លូវលំ និងនាយកដ្ឋាន

ផ្គត់ផ្គង់ទឹកជនបទតែប៉ុណ្ណោះ ហើយថវិកាពីនាយកដ្ឋានផ្លូវលំមានចំនួនច្រើនជាង និងផ្តល់បានច្រើនខេត្តជាងថវិការដ្ឋពីនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ។

របៀបដែលមន្ទីររៀបចំផែនការសំរាប់ថវិកា PIF និងផែនការសំរាប់ថវិការដ្ឋដែលផ្តល់ពីនាយកដ្ឋានផ្លូវលំនិងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ មានវិធីខុសគ្នា ។ យើងឃើញថាមន្ទីរមិនបានយកផែនការ CIP របស់ឃុំមកមើលដើម្បីលើកផែនការជូននាយកដ្ឋានផ្លូវលំ និងនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទទេ ។ ជាទូទៅមន្ទីរបានប្រើមន្ត្រីការិយាល័យ អ.ជ.ប ស្រុក ឬមន្ត្រីការិយាល័យជំនាញថ្នាក់ខេត្ត ចុះសំរង់ទិន្នន័យដើម្បីរៀបចំផែនការ ។ **រីឯការឆ្លើយតបរបស់មន្ទីរទៅនឹងផែនការឃុំ ដោយប្រើប្រាស់ថវិការដ្ឋដែលបានមកពីនាយកដ្ឋានក៏មិនមានលក្ខណៈច្បាស់លាស់ ដូចថវិកា PIF ដែលមន្ទីរបានទទួលពី គ.ប្រ ទេ** ( បញ្ជាក់ : ការឆ្លើយតបរបស់មន្ទីរក្នុងការប្រើថវិកា PIF ទៅឃុំ គឺធ្វើនៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ) ។ បញ្ហាដែលថវិកាពីនាយកដ្ឋានមិនអាចឆ្លើយតបនៅក្នុងសិក្ខាសាលាសមាហរណកម្មនេះ ប្រហែលជាមានការពាក់ព័ន្ធនឹងប្រក្រតិទិនការទំលាក់ថវិកាពីក្រសួងទៅខេត្ត ឬភាពមិនច្បាស់លាស់ដែលមន្ទីរមិនអាចទទួលបានចម្លើយជាវិជ្ជមានទាន់ពេលពីនាយកដ្ឋាន ។ បញ្ហានេះក៏មានកើតឡើងផងដែរនៅក្នុងអង្គការមួយចំនួន ។

មានខេត្តខ្លះការឆ្លើយតបរបស់មន្ទីរមិនបានធ្វើទៅតាមតំរូវការរបស់ឃុំទេ តែតាមការស្នើសុំរបស់អាជ្ញាធរដែនដីថ្នាក់ខេត្ត-ស្រុកទេវិញ ។ នេះជាបញ្ហាមួយលំបាកដែលមន្ទីរមិនអាចនឹងបដិសេធបាន ហើយមន្ទីរក៏គ្មានហេតុផលពន្យល់ទៅឃុំដែលមានអាទិភាពខ្ពស់ ប៉ុន្តែមន្ទីរមិនអាចផ្តល់ការគាំទ្របាន។ ចំពោះឃុំដែលមន្ទីរមិនបានគាំទ្រ មន្ទីរតែងតែពន្យល់ទៅឃុំទាំងនោះវិញថា ចាំឆ្នាំក្រោយឬគំរោងលើកក្រោយ ។ ការឆ្លើយតបទៅឃុំទាំងនោះ មន្ទីរធ្វើឡើងតាមរយៈលិខិតស្នាមទៅប្រធានក្រុមប្រឹក្សាឃុំ ឬការប្រជុំជាទៀងទាត់ណាមួយនៅថ្នាក់ស្រុក ដូចជាការប្រជុំរដ្ឋបាលរបស់អាជ្ញាធរស្រុកជាដើម ប៉ុន្តែក៏មានមន្ទីរខេត្តខ្លះមិនមានយន្តការអ្វីច្បាស់លាស់ទេ ក្នុងការឆ្លើយតបទៅឃុំដែលមន្ទីរមិនអាចគាំទ្របាន ។ **ជាការល្អមន្ទីរគួរប្រើប្រាស់យន្តការការិយាល័យអ.ជ.បថ្នាក់ស្រុក ដើម្បីឆ្លើយតបទៅឃុំដែលលើកសំណើរឡើងមក ហើយមិនបានទទួលការឆ្លើយតបពីមន្ទីរវិញក្នុងការប្រើប្រាស់ថវិការដ្ឋពីនាយកដ្ឋានជំនាញនៅថ្នាក់ជាតិ** ។

**ដើម្បីអោយការលើកផែនការរបស់មន្ទីរជូនទៅថ្នាក់ជាតិក្នុងការប្រើប្រាស់ថវិការដ្ឋ ( ដូចជា នាយកដ្ឋានផ្លូវលំ ) មានលក្ខណៈល្អនិងឆ្លើយតបទៅនឹងផែនការ CIP របស់ឃុំ មន្ទីរត្រូវពិនិត្យមើលតារាង Matrix/CIP របស់ឃុំ និងប្រើបទពិសោធន៍របស់ខ្លួនដែលមានក្នុងការលើកផែនការសុំថវិកា PIF** ។

**បទពិសោធន៍ដ៏ល្អនៃគ.ប្រ ក្រុងកែបបានណែនាំអោយគ្រប់សង្កាត់ឡើងមកបង្ហាញ CIP នៅក្នុងសិក្ខាសាលាមួយនៅថ្នាក់ក្រុង ( សិក្ខាសាលានេះរៀបចំមុនពេលសិក្ខាសាលាសមាហរណកម្មផែនការថ្នាក់ស្រុក ) ដើម្បីអោយមន្ទីរពិនិត្យនិងរៀបចំផែនការរបស់ខ្លួនអោយបានល្អ សំរាប់ដាក់ជូនគ.ប្រពិនិត្យនិងអនុម័ត** ។ នេះជា

ឧទាហរណ៍មួយបង្ហាញថា តើផែនការរបស់មន្ទីរត្រូវធ្វើយ៉ាងណាអោយសមស្របដើម្បីឆ្លើយទៅ CIP របស់ឃុំ ។

**៤.៣. ការប្រើប្រាស់ថវិកា PIF ដើម្បីគាំទ្រគំរោងផ្តល់សេវាកម្ម (ដូចជាការអប់រំអនាម័យ ការបណ្តុះបណ្តាលក្រុមអ្នកប្រើប្រាស់ទឹកស្អាត-អនាម័យ ។ល។) និងគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទ**

តាមការពិនិត្យលើគំរោងផែនការរបស់មន្ទីរហាក់ដូចជាផ្តោតខ្លាំងតែទៅលើការសាងសង់ មិនសូវមានសកម្មភាពដែលទាក់ទងនឹងការអប់រំ ឬរៀបចំ ឬបណ្តុះបណ្តាលគណៈកម្មការអ្វីទេ ។ បញ្ហានេះយើងមើលឃើញផែនការ CIP របស់ឃុំក៏គិតតែពីការសាងសង់ដែរ ដោយមិនសូវយកចិត្តទុកដាក់លើការថែទាំទេ ជាក់ស្តែងផ្លូវក្រាលក្រួសក្រហមមួយខ្សែមានប្រវែង ២.០០០ ម៉ែត្រ នៅក្នុងឃុំគគី ស្រុកមេមត់ ខេត្តកំពង់ចាម សាងសង់ដោយថវិកា PIF បានចាប់ផ្តើមខូចជាបណ្តើរៗដោយគ្មានឃើញឃុំ ឬមន្ទីរលើកផែនការជួសជុលនៅក្នុងផែនការ CIP ឬផែនការមន្ទីរទេ រីឯការរៀបចំគណៈកម្មការថែទាំផ្លូវក៏មិនមានភាពច្បាស់លាស់ដែរ ដោយមន្ត្រីខាងមន្ទីរបានបញ្ជាក់ថា ខាងមន្ត្រីសំរបសំរួលស្រុក (DFT) ជាអ្នករៀបចំដោយមានសមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ២ នាក់ , ចាស់ព្រឹទ្ធាចារ្យ ២ នាក់ , គណៈកម្មការវត្ត ៣ នាក់ និងមេភូមិក្នុងភូមិដែលទទួលផលពីផ្លូវនេះជាសមាជិក ហើយគណៈកម្មការដែលរៀបចំនេះមិនដែលបានទទួលការបណ្តុះបណ្តាល ឬ ណែនាំអ្វីទាំងអស់ពីមន្ទីរ ។ សូម្បីតែគំរោង TRIP ដែលមន្ទីរទទួលខុសត្រូវក៏មានការរៀបចំសមាសភាពគណៈកម្មការថែទាំផ្លូវមិនដូចគ្នាដែរ ។ **នេះជាបញ្ហាមួយដែលក្រុមការងារ សិលា គិតថានាយកដ្ឋានផ្លូវលំ នៃក្រសួង អ.ជ.ប គួរជ្រាបពីបញ្ហានេះ ហើយមានវិធានការដើម្បីណែនាំទៅខេត្ត** ។ ឧទាហរណ៍ជាក់ស្តែងមួយទៀត ក្រុមប្រឹក្សាឃុំលលកស ស្រុកសំពៅមាស ខេត្តពោធិ៍សាត់ បានស្នើសុំអោយមន្ទីរ អ.ជ.ប ជួយបណ្តុះបណ្តាលគណៈកម្មការថែទាំផ្លូវថ្នាក់ភូមិ ។ **ដូច្នេះមន្ទីរគួរពិនិត្យមើលថា តើឃុំណាខ្លះដែលមន្ទីរផ្តល់អាទិភាពសំរាប់បណ្តុះបណ្តាលគណៈកម្មការថែទាំផ្លូវ ដោយប្រើប្រាស់ថវិកា PIF និងឃុំណាដែលត្រូវប្រើប្រាស់មូលនិធិអភិវឌ្ឍន៍ឃុំ ឬក៏ថវិកាផ្សេងរបស់នាយកដ្ឋានផ្លូវលំដែលបានទំលាក់អោយទៅមន្ទីរ** ។

ដើម្បីបំផុសអោយមានការថែទាំផ្លូវបានជិតដល់នៅសហគមន៍ គ.ប្រខេត្តព្រៃវែងបានរៀបចំគណៈកម្មការថែទាំផ្លូវដែលដឹកនាំដោយសហគមន៍ផ្ទាល់ (Local Community Based Organization "LCBO") ។ ដោយប្រើថវិកាគំរោងកម្ចី IFAD គ.ប្របានផ្តល់ ៥០០ USD/មួយឆ្នាំយ៉ាងតិចបំផុតសំរាប់គណៈកម្មការ LCBO ប្រើប្រាស់ក្នុងការថែទាំ នេះជាគំនិតផ្តួចផ្តើមមួយដែលយើងនឹងស្វែងយល់ទាំងអស់គ្នាពីប្រសិទ្ធភាពនៃដំណើការគណៈកម្មការ LCBO ក្នុងការថែទាំផ្លូវ ។

### ៤.៤. កិច្ចសហការនិងការសំរបសំរួលរវាងថវិកា PIF របស់មន្ទីរអ.ជ.ប និងមូលនិធិអភិវឌ្ឍន៍ឃុំ

ជាទូទៅយើងឃើញថាគំរមានគំរោងដែលឃុំប្រើប្រាស់ប្រភពថវិកាពីរចូលគ្នា គឺថវិកា PIF និងថវិកាមូលនិធិឃុំនោះទេ។ ដោយសារថវិកាទាំងពីរនេះមាននិតិវិធីទូទាត់ខុសគ្នា អាចធ្វើអោយមានការលំបាកក្នុងការគ្រប់គ្រង ។ ប៉ុន្តែយើងឃើញមានខេត្តមួយចំនួនសាកល្បងប្រើប្រាស់ថវិកា PIF និងមូលនិធិឃុំចូលគ្នាដែរ ដូចជាខេត្តពោធិ៍សាត់បានសាកល្បងដោយមន្ទីរធនធានទឹកបានបង្វិលថវិកា PIF របស់មន្ទីរខ្លួនចូលទៅក្នុងគណនីឃុំ ក្រោយពីបញ្ចប់ការដេញថ្លៃរួចមក ។ បន្ទាប់មកមន្ទីរធនធានទឹកចាំតែទទួលរបាយការណ៍ពីឃុំ រីឯមន្ទីរមានភារកិច្ចជួយគាំទ្រផ្នែកបច្ចេកទេសលើគំរោងធារាសាស្ត្ររបស់ឃុំនេះ ។ ជាសេចក្តីសន្និដ្ឋានខេត្តបានបញ្ជាក់ថាធ្វើរបៀបនេះមានការលំបាកក្នុងទូទាត់ថវិកាទៅអោយ គ.ប្រ ។

ខេត្តបន្ទាយមានជ័យគេមាននិតិវិធី គឺ រៀបចំគំរោងដាច់ពីគ្នា , មន្ត្រីគាំទ្របច្ចេកទេសជាអ្នកចុះសិក្សាគំរោង , និតិវិធីដេញថ្លៃផ្សេងគ្នា , ការត្រួតពិនិត្យគំរោងក៏ផ្សេងៗគ្នាដែរ និងទូទាត់ថវិកាអោយអ្នកម៉ៅការទៅតាមនិតិវិធីផ្សេងគ្នា ( បញ្ជាក់ : មូលនិធិអភិវឌ្ឍន៍ឃុំ-សង្កាត់ដាក់នៅក្នុងរតនាគារខេត្ត រីឯថវិកា PIF របស់មន្ទីរដាក់នៅធនាគា ) ។

<u>**ប្រសិនបើយើងមាននិតិវិធីច្បាស់លាស់ ក្រុមសិក្សាយល់ឃើញថា គំរោងឃុំមួយដែលជាអាទិភាពបំផុតរបស់ឃុំ ហើយមូលនិធិអភិវឌ្ឍន៍ឃុំមិនគ្រប់ ការបូកបញ្ចូលគ្នារវាងថវិកាអភិវឌ្ឍន៍ឃុំ និងថវិកា PIF គឺមានសារសំខាន់ ។ កន្លងមកយើងឃើញថាឃុំខ្លះបានចំណាយពេលរហូតដល់ទៅ ២-៣ ឆ្នាំទើបសំរេចបានផែនការអាទិភាពមួយរបស់ឃុំគាត់**</u> ។

### ៤.៥. កិច្ចសហការនិង ការទំនាក់ទំនងរវាងក្រុមការងារមន្ទីរអ.ជ.ប និងផ្នែកគាំទ្របច្ចេកទេសនៃគ.ប្រ

ជាទូទៅយើងសង្កេតថាកិច្ចសហការរវាងមន្ទីរ អ.ជ.ប ជាមួយនឹងក្រុមគាំទ្របច្ចេកទេស មិនមានអ្វីច្បាស់លាស់ទេ ។ ខេត្តភាគច្រើនប្រធានផ្នែកគាំទ្របច្ចេកទេស និងប្រធានមន្ទីរ អ.ជ.ប ជាមនុស្សតែមួយ ដូច្នេះការចែករំលែកពតិមានផ្សេងៗរវាងមន្ទីរអ.ជ.បទៅផ្នែកគាំទ្របច្ចេកទេសមានកំរិត ឧទាហរណ៍ការផ្សព្វផ្សាយពីគោលនយោបាយផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ , គោលការណ៍ណែនាំ ស្តីពី ការរៀបចំបង្កើតក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យជាដើម ។ ល ។ បន្ថែមពីលើនេះ យើងក៏មិនឃើញមានយន្តការច្បាស់លាស់ដែរក្នុងការប្រជុំរវាងមន្ត្រីមន្ទីរ អ.ជ.ប ទទួលបន្ទុកថវិកា PIF និងមន្ត្រីទទួលខុសត្រូវផ្នែកគាំទ្របច្ចេកទេសរបស់ គ.ប្រ ឬការចែករំលែករបាយការណ៍-បទពិសោធន៍អោយគ្នាទៅវិញទៅមក ។

<u>**មន្ទីរអ.ជ.ប ត្រូវរៀបចំអោយមានយន្តការច្បាស់លាស់ក្នុងការពង្រឹង កិច្ចសហការរវាងមន្ត្រីមន្ទីរ អ.ជ.ប ទទួលបន្ទុកថវិកា PIF និងផ្នែកគាំទ្របច្ចេកទេសនៃគ.ប្រ ។ ការពង្រឹងកិច្ចសហការនេះមានសារៈ**</u>

**សំខាន់ក្នុងការចែករំលែកបទពិសោធន៍ និងពត៌មានអោយគ្នាទៅវិញទៅមក ។ ជាទូទៅប្រធានមន្ទីរ ឬមន្ត្រីបច្ចេកទេសរបស់មន្ទីរបានទទួលការណែនាំផ្នែកបច្ចេកទេសច្រើន ពីនាយកដ្ឋានជំនាញនៃក្រសួង អ.ជ.ប ដូចជាការរៀបចំគណៈកម្មការថែទាំផ្លូវ ។ល។ ជាដើម ប៉ុន្តែចំណេះដឹង-ពត៌មានដែលពួកគេបានទទួលមិនបានផ្សព្វផ្សាយបន្តទៅអោយមន្ត្រីផ្នែកគាំទ្របច្ចេកទេសបានដឹងទេ ។ បញ្ហានេះកន្លែងខ្លះយើងឃើញថាការរៀបចំគណៈកម្មការមានរូបភាពខុសគ្នា និងមិនមានការទទួលខុសត្រូវច្បាស់លាស់** ។

ក្នុងការអនុវត្តន៍គំរោងដែលប្រើប្រាស់ថវិកា PIF ក្រៅពីមន្ត្រីរបស់មន្ទីរដែលចុះតាមដានការងារនោះ នៅមានមន្ត្រីផ្នែកគាំទ្របច្ចេកទេស , ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ PLG និងមន្ត្រី M&E របស់គ.ប្រក៏បានចុះជួយមន្ទីរក្នុងការត្រួតពិនិត្យគំរោងផងដែរ ។ ការចុះរបស់ផ្នែកពាក់ព័ន្ធខាងលើនេះ ជួនកាលវាមានរូបភាពផ្សេងៗ ដូចជាខេត្តខ្លះបានពោលថា ផ្នែកខ្លះដែលទទួលខុសត្រូវក្នុង គ.ប្រ ហាក់ដូចជាមិនទុកចិត្តសមត្ថភាពមន្ត្រីជំនាញរបស់មន្ទីរទេ ការចុះទៅការដ្ឋាននេះគឺត្រួតពិនិត្យបន្តពីលើអ្វីដែលមន្ត្រីជំនាញរបស់មន្ទីរបានចុះមករួចហើយ ។ **បញ្ហានេះបានធ្វើអោយមន្ត្រីរបស់មន្ទីរខ្លះបាត់បង់ការទទួលខុសត្រូវរបស់ខ្លួន ដោយពួកគេគិតថា ការងាររបស់គេនៅមានអ្នកត្រួតពិនិត្យមួយ-ពីរជាន់ទៀត ដូច្នេះគេតែងតែស្នើសុំអោយផ្នែកទទួលខុសត្រូវរបស់គ.ប្រ ឬទីប្រឹក្សាបច្ចេកទេសរបស់ PLG ចុះជាមួយគ្នាតែម្តង ។ ដើម្បីកសាងភាពជាម្ចាស់ និងមានការជឿជាក់លើសមត្ថភាពរបស់ខ្លួន មន្ត្រីមន្ទីរ អ.ជ.ប គួរតែធ្វើការត្រួតពិនិត្យគុណភាព និងការងារអ្នកម៉ៅការរបស់ខ្លួនអោយបានម៉ត់ចត់ ក្នុងករណីណាមិនច្បាស់លាស់យើងគួរពិភាក្សាជាមួយមន្ត្រីគាំទ្របច្ចេកទេស ឬទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធរបស់ PLG ថ្នាក់ខេត្ត ។ កិច្ចការនេះអាចធ្វើបាននៅពេលដែលមន្ទីរមានយន្តការច្បាស់លាស់ក្នុងការសំរបសំរួល និងសហការជាមួយផ្នែកគាំទ្របច្ចេកទេស** ។

មានសកម្មភាពចាំបាច់មួយចំនួនដែលផ្នែកជំនាញរបស់គ.ប្រត្រូវចុះត្រួតពិនិត្យគំរោង ដូចជានៅពេលមន្ទីរត្រូវចេញអាណត្តិបើកប្រាក់អោយទៅអ្នកម៉ៅការ ។ ការបើកសាច់ប្រាក់អោយអ្នកម៉ៅការបានចែកចេញជាបីដំណាក់ការ គឺ ជំហានទី ១ អ្នកម៉ៅការអាចបើកប្រាក់បាន ៥០ % នៅពេលអនុវត្តការងារបាន ៦០ %, ជំហានទី ២ អ្នកម៉ៅការអាចបើកប្រាក់បន្ថែមបាន ៤៥ % នៅពេលអនុវត្តការងារបាន ១០០ % និង ជំហានទី ៣ អ្នកម៉ៅការអាចបើកប្រាក់ ៥ % ដែលទុកតំកល់សំរាប់ធានាគុណភាពសំណង់រយះពេល ៦ ខែ ។ ការទូទាត់ថវិកាទាំងបីជំហាននេះ អាចធ្វើបានដោយផ្អែកលើផែនការការងារ , កិច្ចសន្យាសាងសង់ , របាយការណ៍រីកចំរើននិងការត្រួតពិនិត្យបច្ចេកទេសពីផ្នែកគាំទ្របច្ចេកទេស និងរបាយការណ៍របស់ផ្នែក M&E គ.ប្រ ។

## V. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

ទោះបីជាមានចំណុចអវិជ្ជមានខ្លះៗក៏ដោយ ក៏យើងឃើញថាចំណុចវិជ្ជមាន មានជាច្រើនដែលមន្ទីរបានខិតខំបំពេញតួនាទី-ភារកិច្ចរបស់ខ្លួនក្នុងការជួយទៅក្រុមប្រឹក្សាឃុំ-សង្កាត់ លើគំរោងហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំសហគមន៍អោយមានការទទួលខុសត្រូវខ្ពស់ ក្នុងការប្រើប្រាស់ និងថែទាំ-គ្រប់គ្រងសមិទ្ធិផលដែលបានមកពីការអភិវឌ្ឍន៍ក្នុងមូលដ្ឋានខ្លួន ។ ដើម្បីជំរុញអោយទស្សនៈ និងគោលបំណងដ៏សំខាន់នេះបានទទួលជោគជ័យកាន់តែខ្ពស់ថែមទៀត ក្រុមការងារ សិលា ដែលបានផ្ដួចផ្ដើមគំនិតចុះសិក្សាស្រាវជ្រាវពីការប្រើប្រាស់ថវិកាវិនិយោគវិស័យ (PIF) របស់មន្ទីរ អ.ជ.ប ក្នុងការគាំទ្រដល់គំរោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ សូមផ្ដល់អនុសាសន៍មួយចំនួនដូចខាងក្រោមនេះ :

១. មន្ទីរអ.ជ.បត្រូវលើកផែនការកសាងសមត្ថភាពមន្ត្រីរបស់ខ្លួន បញ្ចូលទៅក្នុងផែនការមន្ទីរដែលត្រូវស្នើសុំថវិកា PIF ពី គ.ប្រ ។ ការកសាងសមត្ថភាពមន្ត្រីរបស់មន្ទីរនេះ មន្ទីរអាចស្នើសុំធនធានគ្រូពីនាយកដ្ឋានជំនាញទៅបណ្ដុះបណ្ដាលនៅខេត្ត ឬបញ្ជូលមន្ត្រីរបស់ខ្លួនមករៀនជាមួយនឹងអង្គការផ្សេងៗ ។

២. ដើម្បីជួយឃុំក្នុងការគិតគូរពីសេវាថែទាំសមិទ្ធិផល ដែលមានស្រាប់នៅក្នុងមូលដ្ឋានរបស់ខ្លួន មន្ទីរគួរចាត់បញ្ជូនមន្ត្រីជំនាញចុះទៅសង្កេតការនៅថ្នាក់ឃុំ នៅពេលឃុំកំពុងពិនិត្យឡើងវិញពីតំរូវការជាអាទិភាពនៅក្នុង CIP ( ជាពិសេសនៅក្នុងជំហានទី ១ នៃការរៀបចំ CIP ) ។

៣. ក្រុមការងាររបស់មន្ទីរ អ.ជ.ប ដែលទទួលខុសត្រូវថវិកា PIF និងមន្ត្រីផ្នែកគាំទ្របច្ចេកទេស ត្រូវមានការចែករំលែកពត៌មានអោយគ្នាទៅវិញទៅមក តាមរយៈការរៀបចំអោយមានរបបប្រជុំទៀងទាត់ណាមួយក្នុងការចែករំលែកពត៌មានគ្នានេះ ។

៤. មន្ត្រីក្រុមការងាររបស់មន្ទីរ អ.ជ.ប ដែលទទួលខុសត្រូវថវិកា PIF ត្រូវចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលហេដ្ឋារចនាសម្ព័ន្ធជាមួយនឹងមន្ត្រីផ្នែកគាំទ្របច្ចេកទេស ឬសិក្ខាសាលាផ្សេងៗដែលទាក់ទងនឹងការងារហេដ្ឋារចនាសម្ព័ន្ធជនបទ នៅក្នុងក្របខ័ណ្ឌកម្មវិធី សិលា ។

៥. ការឆ្លើយតបរបស់មន្ទីរ អ.ជ.ប ទៅនឹងផែនការឃុំ ដោយប្រើប្រាស់ថវិការដ្ឋដែលនាយកដ្ឋានជំនាញនៅថ្នាក់ជាតិបានផ្ដល់ជូន គួរសំរបសំរួលពេលវេលាអោយបានត្រូវគ្នានៅក្នុងសិក្ខាសាលាសមាហរណកម្មផែនការនៅថ្នាក់ស្រុក ( ក្នុងខែ តុលា នៃឆ្នាំនិមួយៗ ) ។

៦. សុំអោយដំណើរការដេញថ្លៃគំរោងដែលប្រើប្រាស់ថវិកា PIF ចាប់ផ្ដើមធ្វើការដេញថ្លៃនៅដើមឆ្នាំនិមួយៗ ដើម្បីងាយស្រួលក្នុងការអនុវត្តន៏គំរោង ។

៧. ចំពោះឃុំដែលស្នើសុំគំរោងពីមន្ទីរអ.ជ.ប ហើយមិនបានទទួលការគាំទ្រពីមន្ទីរ (ក្នុងករណីគំរោងនេះប្រើថវិការដ្ឋដែលមន្ទីរបានទទួល ពីនាយកដ្ឋានជំនាញនៅថ្នាក់ជាតិ) មន្ទីរត្រូវមានយន្តការច្បាស់លាស់មួយឆ្លើយតបទៅឃុំនោះ ដោយប្រើប្រាស់ការិយាល័យអ.ជ.ប ស្រុក-ខ័ណ្ឌ ។

៨. ដើម្បីអោយការលើកផែនការរបស់មន្ទីរ ជូនទៅនាយកដ្ឋានជំនាញនៅថ្នាក់ជាតិ មានលក្ខណៈច្បាស់លាស់ និងឆ្លើយតបទៅនឹងផែនការ CIP របស់ឃុំ មន្ទីរត្រូវពិនិត្យមើលលើតារាង Matrix/CIP របស់ឃុំ ។ ជាពិសេសមន្ទីរគួរយកបទពិសោធន៍ដែលខ្លួនមាន ក្នុងការលើកផែនការស្នើសុំថវិកា PIF ពីគ.ប្រមកប្រើប្រាស់នៅក្នុងការលើកផែនការទៅអោយថ្នាក់ជាតិ ។

៩. ដោយការគ្រប់គ្រងផ្នែកគាំទ្របច្ចេកទេសនៃគ.ប្រ ក៏ជាបន្ទុកទទួលខុសត្រូវមន្ទីរអ.ជ.ប ដូច្នេះមន្ទីរត្រូវរៀបចំយន្តការអោយបានច្បាស់លាស់ ដើម្បីសហការជាមួយមន្ត្រីផ្នែកគាំទ្របច្ចេកទេស ក្នុងនោះមានដូចជា ការផ្សព្វផ្សាយគោលនយោបាយ ឬគោលការណ៍ណែនាំផ្សេងៗដែលមន្ទីរទទួលបានពីនាយកដ្ឋានជំនាញនៅថ្នាក់ជាតិ ទៅអោយផ្នែកគាំទ្របច្ចេកទេសដឹងឮ និងរួមសហការគ្នាក្នុងការធ្វើការគាំទ្រទៅឃុំ-សង្កាត់ ។

១០. មន្ទីរអ.ជ.បត្រូវចាត់តាំងមន្ត្រីអោយបានច្បាស់លាស់ ក្នុងការទទួលខុសត្រូវអនុវត្តន៍គំរោងដែលប្រើប្រាស់ថវិកា PIF ហើយមន្ត្រីទាំងនោះត្រូវតែមានការទទួលខុសត្រូវខ្ពស់ និងបានទទួលពត៌មានគ្រប់គ្រាន់ក្នុងការអនុវត្តន៍ និងគ្រប់គ្រងថវិកា PIF ។

១១. ត្រូវមានការលើកទឹកចិត្តដល់មន្ត្រីមន្ទីរដែលអនុវត្តគំរោងប្រើប្រាស់ថវិកា PIF ដូចជាការបញ្ជូនពួកគេចូលរួមវគ្គបណ្តុះបណ្តាល ការប្រជុំ ឬសិក្ខាសលាផ្សេងៗក្នុងគោលបំណងដើម្បីកសាងសមត្ថភាព និងពង្រឹងការទទួលខុសត្រូវរបស់ពួកគេ ។

## VI. ឧបសម្ព័ន្ធ

៦.១. តារាងថវិកា PIF មន្ទីរ អ.ជ.ប ទាំង ២៤ ខេត្ត-ក្រុងដែលបានទទួលក្នុងឆ្នាំ ២០០៥ ។

៦.២. បញ្ជីសំណួរ ។

៦.៣. លិខិតឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអ.ជ.ប ក្នុងការណែនាំទៅមន្ទីរ អ.ជ.ប ដើម្បីលើកផែនការសំរាប់ឆ្នាំ ២០០៦-២០០៧ ។

៦.៤. អនុសាសន៍របស់ក្រុមវាយតម្លៃគំរោងផ្គត់ផ្គង់ទឹកស្អាត នៃនាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ។

៦.៥. អនុសាសន៍របស់ក្រុមវាយតម្លៃគំរោងផ្លូវលំ នៃនាយកដ្ឋានផ្លូវលំជនបទ ។

| ល.រ | ខេត្ត | ប្រភេទលទ្ធផលគំរោង និងថវិកា | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | ផ្លូវលំ | លូកាត់ថ្នល់ | ស្ពានថ្ម | ស្ពានឈើ | ទឹកស្អាត | បង្គន់អនាម័យ | អប់រំ/ បណ្តុះបណ្តាល | ចំណាយផ្សេងៗ ដើម្បីគាំទ្រគំរោង |
| 1 | ស្ទឹងត្រែង | $ 35,790.00 | | | | | | | |
| 2 | ក្រចេះ | $ 11,400.00 | | | $ 12,750.00 | | | | |
| 3 | កំពត | ពង្រឹងសមត្ថភាព ទិញម៉ូតូ ឧបករណ៍ សំភារៈ ប្រាក់ឧបត្ថមបុគ្គលិក សេវាកម្មផ្សេងៗ ( ជួសជុលម៉ូតូ ជូនវង្វាន់ .......) | | | | | | | |
| 4 | កំពង់ចាម | $ 18,800.00 | | | | $ 9,180.00 | | | $ 2,020.00 |
| 5 | កែប | | | | | $ 3,700.00 | | $ 752.00 | $ 2,338.00 |
| 6 | ស្វាយ រៀង | $ 24,570.60 | | | | | | | $ 3,026.48 |
| 7 | សៀមរាប | $ 24,000.00 | | | | | | | $ 200.00 |
| 8 | ពោធិ៍សាត់ | $ 5,246.00 | | | | | | | $ 9,754.00 |
| 9 | ព្រៃវែង | | $ 7,591.00 | | | $ 7,385.00 | $ 5,125.00 | | $ 8,322.95 |
| 10 | ព្រះវិហារ | $ 17,000.00 | | | | | | | $ 1,040.00 |
| 11 | ប៉ៃលិន | $ 3,000.00 | | | | $ 2,045.00 | $ 1,050.00 | | $ 455.00 |
| 12 | កំពង់ស្ពឺ | | | | | $ 25,176.00 | | | $ 4,424.00 |
| 13 | កំពង់ឆ្នាំង | $ 10,220.00 | | | | $ 3,147.50 | | | $ 1,577.50 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 14 | កណ្ដាល | $ 34,000.00 | | | | $ 9,000.00 | | | |
| 15 | ក្រុងភ្នំពេញ | | | | | | $ 20,000.00 | | |
| 16 | ក្រុងព្រះសីហនុ | | $ 3,670.64 | | | $ 511.36 | $ 1,754.00 | $ 3,442.38 | $ 1,821.62 |
| 17 | បន្ទាយមានជ័យ | $ 12,740.00 | | | | $ 2,960.40 | $ 5,414.00 | | $ 1,519.60 |
| 18 | បាត់ដំបង | $ 17,670.00 | | | | $ 2,876.40 | $ 5,330.00 | | $ 2,176.60 |
| 19 | តាកែវ | $ 9,716.50 | | | | $ 23,232.30 | | | |
| 20 | ឧត្ដរមានជ័យ | | | | | | | | |
| 21 | កោះកុង | | | | | $ 10,075.80 | | | $ 174.20 |
| 22 | មណ្ឌលគិរី | | | | | | | | |
| 23 | រតនគិរី | | | | | | | | |
| 24 | កំពង់ធំ | | | | | | | | |
| | សរុប | $ 224,153.10 | $ 11,261.64 | $ - | $ 12,750.00 | $ 99,289.76 | $ 38,673.00 | $ 4,194.38 | $ 38,849.95 |

# បញ្ជីសំណួរការសិក្សាវាយតំលៃ ស្តីពី
# ការប្រើប្រាស់មូលនិធិវិនិយោគវិស័យរបស់មន្ទីរអ.ជ.ប
# ក្នុងការគាំទ្រដល់គំរោងអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាឃុំ-សង្កាត់

| ចំណុចផ្តោតនៃពត៌មាន | សំណួរ | អ្នកដែលត្រូវសម្ភាសន៍ |
|---|---|---|
| ១. ដំណើរការរៀបចំសំណើរគំរោងដើម្បីដាក់ជូនទៅ គ.ប្រ សំរាប់ការវិភាជន៍មូលនិធិវិនិយោគខេត្ត ។ | ១. ក្នុងឆ្នាំ ២០០៥ នេះ តើមន្ទីរបានលើកគំរោងអាទិភាពអ្វីខ្លះដើម្បីដាក់ជូន គ.ប្រតិបត្តិនិងសុំការគាំទ្រថវិកា PIF ?<br>២. ក្នុងគំរោងអាទិភាពទាំងនោះ តើមានគំរោងប៉ុន្មានដែលត្រូវប្រើប្រាស់ថវិកា PIF និងមានទឹកប្រាក់ប៉ុន្មាន ? និងគំរោងប៉ុន្មានដែលប្រើថវិការដ្ឋដែលក្រសួងផ្តល់ជូន ឬ គំរោងនៃថវិកាកម្ចី ឬ ជំនួយផ្សេងៗតាមរយៈក្រសួង (ឧទា: ADB, World Bank,... ) ហើយថវិកានោះមានចំនួនប៉ុន្មាន ?<br>៣. តើលោកផ្អែកលើកត្តាអ្វីខ្លះ ដើម្បីកំណត់គំរោងណាមួយដែលត្រូវប្រើប្រាស់ថវិកា PIF ឬ ថវិការដ្ឋដែលក្រសួងផ្តល់ជូន ?<br>៤. សូមរៀបរាប់ពីដំណើរការរៀបចំគំរោង សំរាប់ដាក់ជូនទៅ គ.ប្រតិបត្តិ និងអនុម័តផ្តល់ថវិកា PIF ដើម្បីគាំទ្រគំរោងនោះ ។<br>៥. សូមរៀបរាប់តើមានឯកសារ ឬ ពត៌មានអ្វីខ្លះ ដែលមន្ទីរប្រើសំរាប់រៀបចំគំរោង ។ <u>បញ្ជាក់ :</u> សូមសួរអោយលំអិតរហូតដល់ការវិភាគស្ថានភាពឃុំ ដើម្បីមន្ទីរយកមកប្រើប្រាស់សំរាប់ការរៀបចំគំរោង ។ | ប្រធានមន្ទីរ អ.ជ.ប |
| ២.ការបែងចែកថវិកា PIF ពី គ.ប្រ ទៅអោយមន្ទីរ អ.ជ.ប | ១. តើមន្ទីរអ.ជ.ប មានជនបង្គោលប៉ុន្មាននាក់ដែលទទួលខុសត្រូវក្នុងការអនុវត្តន៍ថវិកា PIF ? សូមរៀបរាប់ពីសមាសភាព, តួនាទី និងការទទួលខុសត្រូវ ។<br>២. តើការបែងចែកនេះ គ/ប្រធានកំណត់លក្ខណៈវិនិច្ឆ័យ | ជនបង្គោលមន្ទីរ អ.ជ.ប |

| | | |
|---|---|---|
| | យ៉ាងដូចម្ដេចខ្លះ ?<br>៣. តើមន្ទីរ អ.ជ.ប មានផែនការអ្វីខ្លះ នៅក្នុងឆ្នាំ ២០០៥ ដែលបានស្នើទៅគ.ប្រ ?<br>៤. តើការកំណត់លក្ខណៈវិនិច្ឆ័យរបស់គ.ប្រ ក្នុងការបែងចែកថវិកា PIF នេះសមស្របតាមផែនការដែលមន្ទីរ អ.ជ.ប បានស្នើដែរឬទេ ?<br>៥. ដើម្បីអោយការបែងចែកថវិកា PIF នេះរឹតតែប្រសើរឡើងថែមទៀត តើលោកមានយោបល់យ៉ាងដូចម្ដេច ? | |
| ៣. ការឆ្លើយតបរបស់មន្ទីរ អ.ជ.បដើម្បីគាំទ្រដល់ផែនការ CIP របស់ឃុំ ។ | ១. តើការឆ្លើយតបរបស់មន្ទីរ អ.ជ.ប ដើម្បីគាំទ្រដល់ផែនការ CIP របស់ឃុំផ្ដែកលើកត្តាអ្វីខ្លះ ?<br>២. តើគំរោងដែលមន្ទីរបានលើកឆ្លើយតបទៅនឹងសំណើររបស់ឃុំនៅក្នុង DIW វាដូចគ្នានឹងគំរោងអាទិភាពដែលមន្ទីរបានលើកជូនគ.ប្រពិនិត្យដើម្បីទទួលថវិកា PIF ដែរឬទេ ? ប្រសិនបើគំរោងនោះខុសគ្នា តើមកពីមូលហេតុអ្វី ?<br>៣. ក្នុងឆ្នាំ ២០០៥ នេះ តើមានគំរោងអាទិភាពរបស់ឃុំប៉ុន្មានដែលមន្ទីរបានលើកបញ្ចូលក្នុងផែនការរបស់ខ្លួន *ដើម្បីប្រើថវិកា PIF* ? ជាគំរោងអ្វីខ្លះ ? អនុវត្តជាក់ស្ដែងបាន ប៉ុន្មាន ? នៅសល់ប៉ុន្មាន ? មកពីមូលហេតុអ្វីបានជា គមរោងដែលសល់នោះអនុវត្តមិនបាន ?<br>៤. ក្នុងឆ្នាំ ២០០៥ នេះ តើមានគំរោងអាទិភាពរបស់ឃុំប៉ុន្មានដែលមន្ទីរបានលើកបញ្ចូលក្នុងផែនការរបស់ខ្លួន ដើម្បីប្រើ *ថវិការដ្ឋដែលក្រសួងផ្ដល់ជូន* ? ជាគំរោងអ្វីខ្លះ ? អនុវត្តជាក់ស្ដែងបានប៉ុន្មាន ? នៅសល់ប៉ុន្មាន ? មកពីមូលហេតុអ្វីបានជាគំរោងដែលសល់នោះអនុវត្តមិនបាន ?<br>៥. ក្នុងឆ្នាំ ២០០៥ នេះ តើមានគំរោងអាទិភាពរបស់ឃុំប៉ុន្មានដែលមន្ទីរបានលើកបញ្ចូលក្នុងផែនការរបស់ខ្លួន ដើម្បីប្រើ *ថវិកាកម្ចី ឬ ជំនួយផ្សេងៗតាមរយៈក្រសួង* ( ឧទា: ADB, World Bank ) ? ជាគំរោងអ្វីខ្លះ ? អនុវត្តជាក់ស្ដែងបានប៉ុន្មាន ? នៅសល់ប៉ុន្មាន ? មកពីមូលហេតុអ្វី | ជនបង្គោលមន្ទីរ អ.ជ.ប |

| | | |
|---|---|---|
| | បានជាគំរោងដែលសល់នោះអនុវត្តមិនបាន ?<br>៦. ថវិកា PIF ដែលនៅសល់ពីឆ្នាំកន្លងទៅ តើមន្ទីរបានយកថវិកានោះទៅធ្វើអ្វីទៀត ? ហើយការធ្វើនោះវាមាននៅក្នុងផែនការដែរឬទេ ? បើមិនមាននៅក្នុងផែនការ តើមកពីមូលហេតុអ្វី ?<br>៧. តើមន្ទីរ អ.ជ.ប មានដំណោះស្រាយយ៉ាងដូចម្តេច ចំពោះឃុំដែលពុំបានទទួលការគាំទ្រពីមន្ទីរ ?<br>៨. តើលោកមានចំណុចអ្វីផ្សេងៗទៀតទេ ដែលមិនទាន់បាននិយាយ ឬពិភាក្សាគ្នាជាមួយនឹងក្រុមយើងខ្ញុំ (ក្រុមអ្នកធ្វើសម្ភាសន៍) ។<br>៩. តើលោកមានអនុសាសន៍អ្វីទេ ដើម្បីកែលំអរ ឬពង្រឹងចំណុចដែលលោកមើលឃើញថាខ្វះខាត ។ | - |

គោលបំណងទី ២ : ស្វែងយល់ពីប្រសិទ្ធិភាពនៃការប្រើប្រាស់ថវិកា PIF របស់មន្ទីរ អ.ជ.ប ក្នុងការឆ្លើយតបទៅនឹងតំរូវការរបស់ឃុំ-សង្កាត់ និងកិច្ចសហការ-សំរបសំរួលរបស់មន្ទីរ អ.ជ.ប ក្នុងការប្រើប្រាស់ថវិកា PIF និងថវិកាមូលនិធិឃុំសង្កាត់ (C/S Fund) របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

| ចំណុចផ្តោតនៃពត៌មាន | សំណួរ | អ្នកដែលត្រូវសម្ភាសន៍ |
|---|---|---|
| ១. ការប្រើប្រាស់ថវិកា PIF ដើម្បីផ្តល់សេវាកម្មដល់ឃុំ | ១. តើមន្ទីរ អ.ជ.ប មានថវិកា PIF ប៉ុន្មានសំរាប់គំរោងផ្តល់សេវាកម្មដល់ឃុំ តាមផែនការអាទិភាពដែលឃុំបានលើក ? ហើយគំរោងផ្តល់សេវាកម្មនោះមានអ្វីខ្លះ<br>២. ក្នុងចំណោមកិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលមន្ទីរបានចុះហត្ថលេខាជាមួយឃុំ តើមានគំរោងផ្តល់សេវាកម្មប៉ុន្មាន ? ជាគំរោងអ្វីខ្លះ ? ។<br>៣. ក្រៅពីមន្ត្រីមន្ទីរ អ.ជ.ប តើអ្នកណាជួយត្រួតពិនិត្យនិងតាមដានការផ្តល់សេវាកម្មនេះ ?<br>៤. តើនិតិវិធីដកថវិកាដើម្បីយកមកអនុវត្ត គំរោងផ្តល់សេវាកម្មទាំងអស់នេះធ្វើឡើងដោយរបៀបណា ?<br>៥. តើសហគមន៍មានចូលរួមអ្វីទេ នៅក្នុងគំរោងដែលមន្ទីរគាំទ្រ ? | ជនបង្គោលមន្ទីរ អ.ជ.ប |

| | | |
|---|---|---|
| **២. ការប្រើប្រាស់ថវិកា PIF ដើម្បីគាំទ្រគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទ ដល់ឃុំ ។** | ១. តើមន្ទីរមានថវិកា PIF ប៉ុន្មានសំរាប់គាំទ្រគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទដល់ឃុំ តាមផែនការអាទិភាពដែលឃុំបានលើកឡើង ?<br>២. ក្នុងចំណោមកិច្ចព្រមព្រៀងបណ្តោះអាសន្ន ដែលមន្ទីរបានចុះហត្ថលេខាជាមួយឃុំ តើមានគំរោងហេដ្ឋារចនាសម្ព័ន្ធប៉ុន្មាន ? ជាគំរោងអ្វីខ្លះ ? អ្នកណាជាអ្នកសិក្សា<br>៣. តើនិតិវិធីដេញថ្លៃធ្វើយ៉ាងដូម្តេច ?<br>៤. ក្រៅពីមន្ត្រីមន្ទីរអ.ជ.ប តើអ្នកណាជាអ្នកជួយតាមដាន និង ត្រួតពិនិត្យការអនុវត្តន៍ គំរោងហេដ្ឋារចនាសម្ព័ន្ធជនបទនេះ ?<br>៥. តើគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទនេះ ឆ្លើយតបតាមតំរូវការ និងផែនការ CIP របស់ឃុំដែរឬទេ ?<br>៦. តើនិតិវិធីដកថវិកាវិនិយោគបែបនេះ ធ្វើឡើងយ៉ាងដូចម្តេចដែរ ?<br>៧. តើលោកមានបញ្ហាអ្វីផ្សេងៗទៀតទេ ដែលមិនទាន់បាននិយាយ ឬ ពិភាក្សាគ្នាជាមួយនឹងក្រុមយើងខ្ញុំ (ក្រុមអ្នកធ្វើសម្ភាសន៍) ។<br>៨. តើលោកមានអនុសាសន៍អ្វីទេ ដើម្បីកែលំអរ ឬពង្រឹងចំណុចដែលលោកមើលឃើញថាខ្វះខាត ។ | ជនបង្គោលមន្ទីរ អ.ជ.ប |
| ៣. កិច្ចសហការ និងការសំរបសំរួល រវាងថវិកា PIF របស់មន្ទីរ អ.ជ.ប និងមូលនិធិឃុំ-សង្កាត់ (C/SF) ។ | ១. តើមានការប្រើប្រាស់ថវិកាចូលគ្នារវាងថវិកា PIF និង C/S Fund ដែរឬទេ ដើម្បីគាំទ្រគំរោងមួយ ? បើមានតើអ្នកប្រើនិតិវិធីយ៉ាងដូម្តេច?<br>២. នៅក្នុងយន្តការនៃការប្រើប្រាស់ថវិកាចូលគ្នាបែបនេះ តើអ្នកណាជាអ្នកសិក្សាគំរោង ?<br>៣. តើនិតិវិធីដេញថ្លៃធ្វើយ៉ាងដូម្តេច ?<br>៤. តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង និង ត្រួតពិនិត្យតាមដានពេលអនុវត្តគំរោង ?<br>៥. តើអ្នកណាជាម្ចាស់គំរោងនោះ ?<br>៦. តើនិតិវិធីទូទាត់ថវិកាអោយអ្នកម៉ៅការ ត្រូវធ្វើយ៉ាង | ជនបង្គោលមន្ទីរ អ.ជ.ប |

| | | |
|---|---|---|
| | ដូចម្តេច ?<br>៧. តើលោកមានបញ្ហាអ្វីផ្សេងៗទៀតទេ ដែលមិនទាន់បាននិយាយ ឬ ពិភាក្សាគ្នាជាមួយនឹងក្រុមយើងខ្ញុំ ។<br>៨. តើលោកមានអនុសាសន៍អ្វីទេ ដើម្បីកែលំអរ ឬពង្រឹងចំណុចដែលលោកមើលឃើញថាខ្វះខាត ។ | |

គោលបំណងទី ៣ : ស្វែងយល់ពីកិច្ចសហការ និង ការទំនាក់ទំនងរវាងមន្ទីរអ.ជ.ប និង ផ្នែកគាំទ្របច្ចេកទេសនៃគណៈកម្មាធិការប្រតិបត្តិ ។

| ចំណុចផ្តោតនៃពត៌មាន | សំណួរ | អ្នកដែលត្រូវសម្ភាសន៍ |
|---|---|---|
| ១. **កិច្ចសហការនិងការទំនាក់ទំនងរវាងជនបង្គោលនៃមន្ទីរ អ.ជ.ប និង មន្ត្រីផ្នែកគាំទ្របច្ចេកទេសនៃគ.ប្រ ។** | ១. តើអ្នកណាជាប្រធាន និង ជាអនុប្រធានផ្នែកគាំទ្របច្ចេកទេស ?<br>២. តើមានការប្រជុំជាទៀងទាត់ទេ វវាងជនបង្គោលរបស់មន្ទីរដែលទទួលខុសត្រូវថវិកា PIF និងមន្ត្រីផ្នែកគាំទ្របច្ចេកទេស ? បើមាន តើប៉ុន្មានខែប្រជុំម្តង ?<br>៣. តើមន្ទីរមានការផ្សព្វផ្សាយ ឯកសារគោលការណ៍អ្វីខ្លះទៅដល់មន្ត្រីផ្នែក TSU ?<br>៤. តើមានការផ្តល់ពត៌មាន តាមរយះរបាយការណ៍របស់ផ្នែក TSU ទៅជនបង្គោលរបស់មន្ទីរដែរឬទេ ? បើមាន តើទៀងទាត់ទេ ហើយប៉ុន្មានខែម្តង ?<br>៥. តើមានការបណ្តុះបណ្តាលពង្រឹង សមត្ថភាពអ្វីខ្លះដល់ជនបង្គោលរបស់មន្ទីរ ?<br>៦. តើលោកមានបញ្ហាអ្វីផ្សេងៗទៀតទេ ដែលមិនទាន់បាននិយាយ ឬ ពិភាក្សាគ្នាជាមួយនឹងក្រុមយើងខ្ញុំ ( ក្រុមអ្នកធ្វើសម្ភាសន៍ ) ។<br>៧. តើលោកមានអនុសាសន៍អ្វីទេ ដើម្បីកែលំអរ ឬពង្រឹងចំណុចដែលលោកមើលឃើញថាខ្វះខាត ។ | ប្រធានមន្ទីរ អ.ជ.ប |

**ការពង្រឹងគុណភាពតាមរយៈការសម្ភាសន៍អ្នកពាក់ព័ន្ធ**

ក្រោយពីការសម្ភាសន៍ជាមួយនឹងក្រុមគោលដៅផ្ទាល់រួចមក ក្រុមការងារដែលចុះសិក្សានឹងធ្វើការសាកសួរសំណួរមួយចំនួនទៅក្រុមគោលដៅប្រយោល ដែលមានសមាសភាពដូចជា មន្ត្រី PLG នៅថ្នាក់ខេត្តដែលទទួលបន្ទុកថវិកា PIF និងមន្ត្រី CAU នៃគណៈកម្មាធិការប្រតិបត្តិ ។ សំណួរមានដូចខាងក្រោមនេះ :

| ក្រុមគោលដៅប្រយោល | សំណួរ | គោលបំណងនៃការសិក្សា |
|---|---|---|
| មន្ត្រី PLG ទទួលបន្ទុកថវិកា PIF និងមន្ត្រី CAU នៃគ.ប្រ | ១. តើការបែងចែកនេះ គ/ប្រធានកំណត់លក្ខណៈវិនិច្ឆ័យយ៉ាងដូចម្តេចខ្លះ ?<br>២. តើការកំណត់លក្ខណៈវិនិច្ឆ័យរបស់គ.ប្រ ក្នុងការបែងចែកថវិកា PIF នេះសមស្របតាមផែនការដែលមន្ទីរអ.ជ.ប បានស្នើដែរឬទេ ?<br>៣. តើការឆ្លើយតបរបស់មន្ទីរ អ.ជ.ប ដើម្បីគាំទ្រដល់ផែនការ CIP របស់ឃុំផ្តែកលើកត្តាអ្វីខ្លះ ?<br>៤. តើមន្ទីរអ.ជ.ប បានអនុវត្តថវិកា PIF តាមផែនការដែរឬទេ ? បើមិនតាមផែនការ តើមកពីមូលហេតុអ្វី ?<br>*<u>បញ្ជាក់</u>* : ផ្ទៀងផ្ទាត់រវាងសំណើគំរោងដែលមន្ទីរបានដាក់ជូន គ.ប្រពិនិត្យសំរាប់ការវិភាជន៍ថវិកា PIF និងកិច្ចព្រមព្រៀងបណ្តោះអាសន្នដែលមន្ទីរបានធ្វើជាមួយឃុំ នៅក្នុងសិក្ខាសាលា DIW ។<br>៥. តើអ្នកណាជួយត្រួតពិនិត្យនិងតាម ដានការផ្តល់សេវាកម្ម និងគំរោងហេដ្ឋារចនាសម្ព័ន្ធនេះ ?<br>៦. តើការផ្តល់សេវាកម្ម និងគំរោង Infra នេះវាឆ្លើយតបទៅនឹងផែនការ CIP របស់ឃុំទេ ?<br>៧. តើការទទួលទាក់លើលទ្ធផលគំរោងទាំងនោះ ផ្អែកលើកត្តាអ្វីខ្លះ ?<br>៨. តើលោកមានចំណុចអ្វីផ្សេងៗទៀតទេ ដែលមិនទាន់បាននិយាយ ឬ ពិភាក្សាគ្នាជាមួយនឹងក្រុមយើងខ្ញុំ ( ក្រុមអ្នកធ្វើសម្ភាសន៍ ) ។<br>៩. តើលោកមានអនុសាសន៍អ្វីទេ ដើម្បីកែលំអរ ឬពង្រឹងចំណុចដែលលោកមើលឃើញថាខ្វះខាត ។ | គោលបំណងទី ១ , ២ និងទី ៣ |

| | | |
|---|---|---|
| ក្រុមប្រឹក្សាឃុំ | ១. សំរាប់ឆ្នាំ ២០០៥ , តើលោកមេឃុំមានគំរោងសេវាកម្មប៉ុន្មាន គំរោងហេដ្ឋារចនាសម្ព័ន្ធប៉ុន្មាន ដែលស្ថិតនៅក្នុងកិច្ចព្រមព្រៀងរវាងមន្ទីរ អ.ជ.ប និង ឃុំ ? តើគំរោងដែលបានចុះកិច្ចសន្យាបណ្តោះអាសន្នទោះ វាឆ្លើយតបនឹងគំរោងអាទិភាពរបស់ឃុំទេ ? បើវាមិនឆ្លើយតប តើវាមកពីមូលហេតុអ្វី ?<br>២. តើមានគំរោងហេដ្ឋារចនាសម្ព័ន្ធជនបទ និង សេវាកម្មអ្វីខ្លះដែលមន្ទីរបានគាំទ្រដល់ឃុំលោក ?<br>៣. តើមានការប្រើប្រាស់ថវិកាចូលគ្នារវាងថវិកា PIF និង C/S Fund ដែរឬទេ ដើម្បីគាំទ្រគំរោងមួយនៅក្នុងឃុំលោក ? បើមានតើអ្នកប្រើនិតិវិធីយ៉ាងដូម្តេច ? ហើយអ្នកណាជាម្ចាស់គំរោងនោះ ? តើគណៈកម្មការលទ្ធកម្មឃុំលោក បានចូលរួមត្រួតពិនិត្យគំរោងដែរឬទេ ?<br>៤. តើលោកមានបញ្ហាអ្វីផ្សេងៗទៀតទេ ដែលមិនទាន់បាននិយាយ ឬពិភាក្សាគ្នាជាមួយនឹងក្រុមយើងខ្ញុំ ( ក្រុមអ្នកធ្វើសម្ភាសន៍ ) ។<br>៥. តើលោកមានអនុសាសន៍អ្វីទេ ដើម្បីកែលំអរឬពង្រឹងចំណុចដែលលោកមើលឃើញថាខ្វះខាត ។ | គោលបំណងទី ១ , ២ និងទី ៣ |
| | | |

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ០៧០/០៥ ក.អ.ជ

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

## ជំរាបមក

## លោក ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ទាំង ២៤ ខេត្ត-ក្រុង

**កម្មវត្ថុ** : ការផ្តល់មតិណែនាំក្នុងការរៀបចំសកម្មភាពសំខាន់ៗ សំរាប់ផែនការមន្ទីរ អ.ជ.ប ឆ្នាំ ២០០៦ ក្នុងការប្រើប្រាស់ថវិកាវិភាជន៍របស់គណៈកម្មាធិការប្រតិបត្តិខេត្ត-ក្រុង ។

សេចក្តីដូចបានចែងតាមកម្មវត្ថុខាងលើ និងយោងតាមលទ្ធផលការសិក្សារបស់ក្រុមការងារកម្មវិធីសិលា ក្រសួងអ.ជ.ប ដែលបានធ្វើទៅលើខេត្ត ៧ ជាតំណាងអោយខេត្ត-ក្រុងទាំង ២៤ ទូទាំងប្រទេស យើងឃើញថាការលើកផែនការរបស់មន្ទីរ អ.ជ.ប ហាក់ដូចជាមិនទាន់មានភាពរលូនជាមួយនឹងសកម្មភាពដែលជាសមត្ថកិច្ចរបស់ក្រសួង អ.ជ.ប ក្នុងការគាំទ្រផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ដើម្បីអោយការលើកផែនការឆ្នាំ ២០០៦-២០០៧ របស់មន្ទីរ អ.ជ.ប មានលក្ខណៈសមស្រប និងឆ្លើយតបទៅនឹងសមត្ថកិច្ចរបស់ក្រសួងអ.ជ.ប ខ្ញុំសូមធ្វើការណែនាំសកម្មភាពការងារសំខាន់ៗមួយចំនួនសំរាប់ថ្នាក់ដឹកនាំមន្ទីរពិចារណាក្នុងការបញ្ចូលទៅក្នុងផែនការរបស់មន្ទីរខ្លួនឆ្នាំ ២០០៦-២០០៧ ដើម្បីបានទទួលថវិកាវិភាជន៍ពីគណៈកម្មាធិការប្រតិបត្តិខេត្ត-ក្រុងទូទាំងប្រទេស ។

សេចក្តីណែនាំមានដូចខាងក្រោមនេះ :

១. **សកម្មភាពផ្លូវលំ**

- ការបង្កើតគណៈកម្មការថែទាំផ្លូវលំថ្នាក់ឃុំ-សង្កាត់ និងភូមិ ។
- ការបណ្តុះបណ្តាលសមាជិកគណៈកម្មការថែទាំផ្លូវលំថ្នាក់ឃុំ-សង្កាត់ ។
- ការចុះស្រង់ទិន្នន័យផ្លូវលំដែលស្ថាបនាដោយថវិកាមូលនិធិឃុំ-សង្កាត់ ។
- រៀបចំសាងសង់ ឬជួសជុលបង្គោលសុវត្ថិភាព ដោយបំពាក់របាំងពីលើ ។
- ជួសជុល-ថែទាំការខូចខាតតូចតាចតាមសំណង់សិល្បការ ដូចជាស្រុតដីក្បាលស្ពាន ។ល។

អាស័យដ្ឋាន : កាច់ជ្រុងវិថីលេខ ១៦៩ និង មហាវិថី សហព័ន្ធរុស្សី ប្រអប់សំបុត្រលេខ ២០១៦ ភ្នំពេញ
ទូរសារ និង ទូរស័ព្ទ : (៨៥៥) ២៣ ៨៦៦ ៨៩០ / (៨៥៥) ២៣ ៨៨៤ ៦៣៤

- ចុះតាមដានការងារសាងសង់ និងថែទាំផ្លូវលំ និងពង្រឹងសមត្ថភាពគណៈកម្មការថែទាំផ្លូវថ្នាក់ឃុំ ។

២. សកម្មភាពផ្គត់ផ្គង់ទឹកស្អាត

- ការបង្កើតក្រុមអ្នកប្រើប្រាស់ទឹកស្អាតនិងអនាម័យតាមចំណុចអណ្តូង និងបណ្តុះបណ្តាលក្រុមនេះអោយចេះជួសជុលតូចតាច នៅពេលស្ទះអណ្តូងខូច ។
- ការចុះស្រង់ទិន្នន័យអណ្តូងខូចដែលប្រើប្រាស់លែងកើត ។
- ការធ្វើតេស្តសារធាតុ អាសេនិច នៅក្នុងទឹកអណ្តូង ។
- ការដោះស្រាយរកប្រភពទឹកស្អាតសំរាប់ហូប ដូចជាការចែកធុងចំរោះ ដោយមានការចូលរួមថវិកាពីសហគមន៍ ។
- សិក្សាស្រាវជ្រាវប្រភពទឹកដែលមានស្រាប់ ។
- ត្រួតពិនិត្យសកម្មភាពបច្ចេកទេសអ្នកម៉ៅការសាងសង់អណ្តូង និងពង្រឹងក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ។

៣. សកម្មភាពអប់រំសុខភាព-អនាម័យ

- បណ្តុះបណ្តាលដល់ក្រុមអ្នកប្រើប្រាស់ទឹកស្អាតនិងអនាម័យ ស្តីពីការអប់រំអនាម័យនិងប្រើប្រាស់ទឹកស្អាត ។
- ការអប់រំបញ្ហា អាសេនិច ដែលប៉ះពាល់ដល់សុខភាពអ្នកប្រើប្រាស់ទឹកអណ្តូង ។
- ការអប់រំសុខភាព ស្តីពី ការទប់ស្កាត់ការរីកដាលនៃជំងឺ អេដស៍ និងការថែទាំសុខភាពជាមូលដ្ឋានផ្សេងៗ ។
- ការចុះសំរង់ទិន្នន័យបង្គន់អនាម័យតាមគ្រួសារ-សាលារៀន ។
- ចុះតាមដានការងារនៅមូលដ្ឋាន ដោយរួមទាំងការពង្រឹងក្រុមអ្នកប្រើប្រាស់ទឹកស្អាត និងអនាម័យ , ភ្នាក់ងារសុខភាពស្ម័គ្រចិត្តភូមិ ។ល។

៤. សកម្មភាពកសាងសមត្ថភាពមន្ត្រីរាជការថ្នាក់ខេត្ត-ស្រុក

- ចូលរួមវគ្គបណ្តុះបណ្តាលខ្លីៗ ដែលរៀបចំឡើងដោយនាយកដ្ឋានពាក់ព័ន្ធនៅថ្នាក់ជាតិ ។
- វគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ ដូចជា ការប្រើប្រាស់ Computer ។ល។
- ចូលរួមប្រជុំ-សិក្ខាសាលាផ្សេងៗ ដែលរៀបចំឡើងដោយនាយកដ្ឋានជំនាញនានា ។
- ផ្សព្វផ្សាយគោលនយោបាយ , គោលការណ៍ណែនាំ និង លិខិតបទដ្ឋានផ្លូវច្បាប់នានា ដែលទាក់ទងនឹងសមត្ថកិច្ចក្រសួង អ.ជ.ប ដល់ស្ថាប័ន-ផ្នែកពាក់ព័ន្ធនៅថ្នាក់ខេត្ត-ក្រុង

ដើម្បីអោយថ្នាក់ដឹកនាំមន្ទីរមានគំនិតជាមូលដ្ឋានកាន់តែច្បាស់ថែមទៀត នាយកដ្ឋានជំនាញនឹងរៀបចំបែបបទនិតិវិធីផ្សេងៗ ដើម្បីណែនាំដល់មន្ទីរ អ.ជ.ប ក្នុងការអនុវត្តន៍សកម្មភាពសំខាន់ៗទាំងនោះ ។ ក្នុងករណីដែលមានចម្ងល់ និងបញ្ហាអ្វីមួយ សូមអោយលោកប្រធានមន្ទីរទំនាក់ទំនងមកអគ្គនាយកបច្ចេកទេស និង នាយកដ្ឋានជំនាញដើម្បីស្វែងយល់អោយកាន់តែច្បាស់ ។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមលោកប្រធានមន្ទីរ អ.ជ.ប មេត្តាចាត់ចែងអនុវត្តតាមការណែនាំនេះអោយមានប្រសិទ្ធភាព ។

សូមលោតប្រធានមន្ទីរទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

លឺ-ឡាយស្រេង

ចម្លងជូន

-ឯកឧត្តម រដ្ឋលេខាធិការបច្ចេកទេស-ក.អ.ជ.

-ឯកឧត្តម អភិបាលខេត្ត-ក្រុង និងជាប្រធាន
នៃគណៈកម្មាធិការប្រតិបត្តិគ្រប់ខេត្ត-ក្រុង

-អគ្គនាយកដ្ឋានបច្ចេកទេស-ក.អ.ជ

-អគ្គលេខាធិការដ្ឋាន STF

-នាយកដ្ឋានពាក់ព័ន្ធ-ក.អ.ជ

-ក្រុមការងារកម្មវិធី សិលា-ក.អ.ជ

-PLG-ភ្នំពេញ និងខេត្ត-ក្រុងទាំង ២៤

-អង្គការពាក់ព័ន្ធនានានៅថ្នាក់ជាតិ និងខេត្ត-ក្រុង

-ប័ណ្ណសារ-កាលប្បវត្តន៍

# អនុសាសន៍របស់ក្រុមសិក្សា
# នាយកដ្ឋានផ្លូវលំជនបទ ស្តីពី
# ការសាងសង់ផ្លូវលំដោយប្រើប្រាស់មូលនិធិឃុំ-សង្កាត់
# នៅខេត្តព្រះវិហារ កំពង់ចាម បន្ទាយមានជ័យ និងខេត្តសៀមរាប
# ថ្ងៃទី ១៦ ឧសភា - ៩ មិថុនា ២០០៥

---

អនុសាសន៍

១. គួរមានឧបករណ៍ធ្វើតេស្តការងារបង្ហាប់ដី ។

២. នាយកដ្ឋានផ្លូវលំជនបទ ត្រូវបញ្ចប់សេចក្តីបញ្ជាក់បច្ចេកទេស ស្តីពី ការបង្ហាប់ដី និងផ្សព្វផ្សាយទៅគ្រប់មន្ទីរអ.ជ.ប ។

៣. គួរអប់រំប្រជាពលរដ្ឋឱ្យស្គាល់ពីសារៈសំខាន់នៃផ្លូវ និងចេះជួយថែរក្សាទាំងអស់គ្នា ។

៤. ផ្លូវត្រូវមានបង្គោលការពារសុវត្ថិភាព ។

៥. ត្រូវជំរុញឱ្យគណកម្មាធិការថែទាំផ្លូវដែលបានបង្កើតឱ្យមានសកម្មភាព ។

៦. ចំពោះសំណង់លូដែលមានប្រវែងស្មើទទឹងផ្លូវ កំពស់ក្បាលលូត្រូវលើកឱ្យផុតពីតួផ្លូវឱ្យបាន ០.២ ម៉ែត្រ ។

៧. ប្រវែងលូ ត្រូវតែវែងជាងទទឹងរបស់ផ្លូវ ។

៨. ត្រូវកំណត់ទំងន់រថយន្តឱ្យឆ្លងកាត់ផ្លូវ ។

៩. ប្រសិនបើធ្វើផ្លូវថ្មី គួរតែធ្វើទទឹងផ្លូវឱ្យមានទំហំធំបន្តិចចាប់ពី ៥ - ៧ម៉ែត្រ ។

១០. ប្រសិនបើផ្លូវមានទទឹង ៣ ឬ ៤ ម៉ែត្រ គួរតែមានផ្លូវសំរាប់បញ្ចៀសរថយន្តក្នុងប្រវែង ៥០០ ម៉ែត្រមួយ ។

១១. កាលណាចំនួនចរាចរច្រើន យើងគួរជ្រើសរើសប្រភេទកំរាលផ្សេងៗ ដូចជា កំរាលបេតុង D.B.S.T, បេទីមីន័រ ទៅលើផ្លូវដែលឆ្លងកាត់ទីប្រជុំជន ។ តាមការពិនិត្យជាក់ស្តែងយើងឃើញថាផ្លូវដែលបានកសាងក្នុងឆ្នាំ ២០០៤ វាខូចច្រើនជាងផ្លូវដែលបានកសាងនៅឆ្នាំ ២០០៣ ដោយសារចំនួនចរាចរ ។

១២. គួរតែជំរុញឱ្យមន្ត្រីគាំទ្របច្ចេកទេសត្រួតពិនិត្យឡើងវិញឱ្យបានដិតដល់នៅពេលធ្វើរបាយការណ៍បញ្ចប់គំរោង ។

១០. អណ្តូងណាមួយដែលមានទីតាំងលើដីឯកជន ត្រូវមានច្រកទ្វារចូលពីខាងក្រៅទៅអណ្តូងនោះដោយផ្ទាល់ ។

១១. អណ្តូងណាមួយដែលមានទីតាំងលើដីឯកជន ត្រូវតែមានកិច្ចសន្យារវាងម្ចាស់ដី និងក្រុមអ្នកប្រើប្រាស់ទឹក ដើម្បីបង្ហាញថា ម្ចាស់ដីបានយល់ព្រមអនុញ្ញាតិអោយបើកច្រកទ្វារបងទៅអណ្តូង សំរាប់អ្នកប្រើប្រាស់ចេញចូលបានស្រួល ដោយមានប្រធានភូមិ និង ក្រុមប្រឹក្សាឃុំ ធ្វើជាសាក្សី ។

១២. គ្រួសារប្រើប្រាស់ទឹកអណ្តូងទាំងអស់ គួរតែចូលរួមទុនជាសាច់ប្រាក់ទៅលើតំលៃសាងសង់អណ្តូង ទោះបីជាគ្រួសារក្រីក្របំផុតក៏ដោយ ក៏ត្រូវចូលរួមតិចតួចផងដែរ ។

១៣. គ្រប់អណ្តូងទាំងអស់ ត្រូវតែអនុវត្តតាមដំណើរការរៀបចំគំរោង និងការបញ្ជាក់បច្ចេកទេសច្បាស់លាស់រួមបញ្ចូលទាំងអណ្តូងដែលបាន ធ្វើសល់ពីថវិកាបន្ទាប់ពីការដេញថ្លៃ ។ ត្រូវរៀបចំប្លង់ទីតាំងដែលបានព្រមព្រៀងគ្នាសំរាប់ដាក់អណ្តូង ។

១៤. មន្ទីរអភិវឌ្ឍន៍ជនបទគ្រប់ខេត្ត-ក្រុងមុននឹងបញ្ជាក់បច្ចេកទេសគំរោងអណ្តូង ត្រូវពិនិត្យឯកសារពតិមានពីក្រុមអ្នកប្រើប្រាស់ទឹក គំរោងផែនការដែលត្រូវចូលរួមអនុវត្ត និងចុះពិនិត្យស្ថានភាពអណ្តូងនោះដោយផ្ទាល់

១៥. ប្លង់ទីតាំងអណ្តូងត្រូវតែដាក់បញ្ចូលក្នុងឯកសារកិច្ចសន្យា ។ អ្នកទទួលការត្រូវតែដឹងអោយច្បាស់ថា គ្មានអ្នកណាម្នាក់មានសិទ្ធណែនាំគាត់ អោយដាក់អណ្តូងកន្លែងណាមួយខុសពីទីតាំង ដែលបានបញ្ជាក់ច្បាស់ដោយគ្មានការសរសេរ កែប្រែកិច្ចសន្យានោះទេ ។

១៦. នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ គួរផ្សព្វផ្សាយគោលការណ៍ណែនាំការងារត្រួតពិនិត្យជាក់លាក់ដែលក្រុមអ្នកប្រើប្រាស់ទឹកអាចអនុវត្តបាន ។ ដោយក្នុងនោះមន្ត្រីគាំទ្របច្ចេកទេសជាអ្នកបង្រៀនទៅក្រុមអ្នកប្រើប្រាស់ទឹកអំពីការងារត្រួតពិនិត្យអណ្តូង មុនពេលចាប់ផ្តើមសាងសង់ អំឡុងពេលសាងសង់ និងក្រោយពេលសាងសង់ ។

១៧. ការបណ្តុះបណ្តាល អំពី ការងារថែទាំសាមញ្ញដល់ក្រុមអ្នកប្រើប្រាស់ទឹក គួរតែជាផ្នែកមួយនៃការទទួលខុសត្រូវរបស់អ្នកទទួលការ ។

១៨. ការបំពាក់ស្នប់អណ្តូងទាំងអស់ ត្រូវផ្តល់ឧបករណ៍ជួយសជុលជាមូលដ្ឋានមួយកំប្លេ ។ ចំពោះស្នប់អាហ្វ្រីដេសតំរូវអោយមានគ្រឿងបន្លាស់មួយកំប្លេល្មមគ្រប់គ្រាន់សំរាប់រយៈពេល ២ ឆ្នាំ ។

១៩. នាយកដ្ឋានថែទាំសុខភាពជនបទ ត្រូវផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពី ការអប់រំសុខភាព-អនាម័យ និងប្រើប្រាស់ទឹក ទៅមន្ទីរអភិវឌ្ឍន៍ជនបទ , អង្គការ NGOs , អ្នកម៉ៅការ និងតាមដានការងារអប់រំអនាម័យ និងការប្រើប្រាស់ទឹកនេះ ។

# អនុសាសន៍របស់ក្រុមសិក្សា
# នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ ស្តីពី
# ការសាងសង់អណ្តូងទឹកដោយប្រើប្រាស់មូលនិធិឃុំ-សង្កាត់
# នៅខេត្តក្រចេះ កំពង់ឆ្នាំង បាត់ដំបង និងខេត្តតាកែវ
# ថ្ងៃទី ០៦ ឧសភា - ១០ មិថុនា ២០០៥

អនុសាសន៍

១. គ្រប់កិច្ចសន្យានៃការសាងសង់អណ្តូង ត្រូវតែរួមបញ្ចូលរយៈពេលថែទាំដោយពន្យារហូតដល់រដូវប្រាំងនៃឆ្នាំបន្ទាប់ ។ ក្នុងអំឡុងពេលនៃការធានា ប្រសិនបើអណ្តូងនោះខូច អ្នកទទួលការត្រូវតែត្រលប់មកចំណុចអណ្តូងឡើងវិញដើម្បីអនុវត្តការងារថែទាំជួសជុលឡើងវិញ ។ ការដកសាច់ប្រាក់ចុងក្រោយបានលុះត្រាតែអណ្តូងមានទឹកប្រើគ្រប់គ្រាន់នៅរដូវប្រាំង ។

២. ផ្នែកខួងនៃអណ្តូងចំរុះត្រូវតែសាងសង់ អោយដូចទៅនឹងសេចក្តីបញ្ជាក់បច្ចេកទេសរបស់អន្តូងខួងដែរ ។ លើកលែងតែទំហំអង្កត់ផ្ចិតតូចបំផុតគួរតែ ៦០ម.ម សំរាប់បំពង់ជ្រាប (**Screen** ) ។

៣. ការសាងសង់អណ្តូងស្នប់អាហ្វ្រិដេស គួរតែបញ្ជាក់នៅក្នុងកិច្ចសន្យាថា តើស្នប់ដែលត្រូវយកមកដាក់នោះជាស្នប់ផលិតនៅក្នុងស្រុក ឬនាំចូល ។

៤. រាល់ការផ្លាស់ប្តូរគំនូសប្លង់ផ្សេងៗ ឬប្តូរក្បាលស្នប់អណ្តូងត្រូវធ្វើការកែប្រែក្នុងកិច្ចសន្យា និងក្នុងប្រព័ន្ធទិន្នន័យផង ដើម្បីងាយស្រួលរកទីតាំងលទ្ធផលគំរោង នៅពេលមានក្រុមត្រួតពិនិត្យចុះតាមដានគំរោង ។

៥. គ្រប់អណ្តូងទាំងអស់ ការសាងសង់ដោយអ្នកម៉ៅការគួរតែដាក់គំនូសប្លង់នៃការសាងសង់ របងការពារជុំវិញអណ្តូងបញ្ចូលទៅក្នុងកិច្ចសន្យា ។

៦. គ្រប់អណ្តូងថ្មីទាំងអស់ ការពិសោធន៍គុណភាពទឹក (ជាតិដែក , អតិសុខុមប្រាណ ពិសេសសារធាតុ អាសេនិច) គួរតែអនុវត្តនៅក្នុងរយៈពេលសាងសង់ ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ ក៏ដូចជាអ្នកទទួលការមិនមានសមត្ថភាពក្នុងការធ្វើពិសោធន៍គុណភាពទឹកនេះទេ ។ ដូច្នេះមន្ទីរអភិវឌ្ឍន៍ជនបទគ្រប់ខេត្ត-ក្រុង ត្រូវផ្តល់សេវាកម្មនេះស្របតាមការណែនាំរបស់លេខាធិការដ្ឋាននៃអនុគណៈកម្មការត្រួតពិនិត្យធាតុ អាសេនិច ។

៧. អណ្តូងខួងនីមួយៗត្រូវមានក្រដាស់កត់ត្រាទិន្នន័យ ( **well log sheet** ) ។ មន្ទីរអភិវឌ្ឍន៍ជនបទគ្រប់ខេត្ត-ក្រុង ត្រូវមានក្រដាស់ទិន្នន័យនេះ ដោយរក្សាទុកនៅមន្ទីរ ១ សន្លឹក និងបញ្ជូនមកនាយកដ្ឋាន ផ្គត់ផ្គង់ទឹកជនបទដើម្បីរក្សាទុកក្នុងប្រព័ន្ធទិន្នន័យថ្នាក់ជាតិ ។

៩. ពត៌មាន អំពី ស្ថានភាពអណ្តូង គួរតែសរសេរនៅលើកំរាលអណ្តូងតាមទំរង់ស្តង់ដាមួយ ដែលនឹងត្រូវផ្តល់ការណែនាំដោយនាយកដ្ឋាន ផ្គត់ផ្គង់ទឹកជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ ។